ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

# គោលការណ៍ណែនាំ

# ការបញ្ជ្រាបយេនឌ័រក្នុង ការគ្រប់គ្រងគ្រោះមហន្តរាយ

# ប្រកបដោយបរិយាប័ន្ន

# អារម្ភកថា

បច្ចុប្បន្នមុខសញ្ញាគ្រោះថ្នាក់ គ្រោះមហន្តរាយកាន់តែកើតមានច្រើន និងកើតឡើងថ្មីបន្ថែមទៀតនៅលើពិភពលោកដែលមនុស្សជាតិកំពុងជួបប្រទះ។ ចំពោះព្រះរាជាណាចក្រកម្ពុជាគ្រោះមហន្តរាយបង្កឡើងដោយធម្មជាតិ និងដោយមនុស្សកើតមានរៀងរាល់ឆ្នាំ ហើយការប្រឈមរបស់ប្រជាជនតិចឬច្រើនទៅនឹងគ្រោះមហន្តរាយ អាស្រ័យទៅលើកត្តាសង្គម សេដ្ឋកិច្ច សម្ភារៈនិងភូមិសាស្ត្រនីមួយៗ។

ការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានកសាងនូវសមិទ្ធផលជាច្រើនដែលជាវិធានការក្នុងការត្រៀមបង្ការគ្រោះមហន្តរាយ តាមបែបរចនាសម្ព័ន្ធ និងមិនមែនរចនាសម្ព័ន្ធ ដើម្បីធានាសុវត្ថិភាព សុខុមាលភាព ជីវភាពរស់នៅរបស់ប្រជាជន និងការអភិវឌ្ឍជៀសផុតពីគ្រោះមហន្តរាយ។ ហើយនៅពេលកើតមានគ្រោះមហន្តរាយ ការឆ្លើយតប សង្គ្រោះបន្ទាន់ត្រូវបានការយកចិត្តទុកដាក់ខ្ពស់ នឹងមិនទុកចោលប្រជាជនណាម្នាក់ដោយមិនមានការទទួលខុសត្រូវឡើយ។ ជាចម្បងត្រូវបានគិតគូរស្ត្រី កុមារ ចាស់ជរា ជនមានពិការភាព ដែលជាក្រុមងាយរងគ្រោះ ហើយស្ត្រីក៏មានខ្លះទទួលបន្ទុករ៉ាប់រងធ្ងន់ធ្ងរទៅលើក្រុមងាយរងគ្រោះនេះទៀតផង ទាំងនៅមុនពេល ក្នុងពេល និងក្រោយពេលគ្រោះមហន្តរាយ។

ការបញ្ជ្រាបយេនឌ័រទៅក្នុងការគ្រប់គ្រងគ្រោះមហន្តរាយប្រកបដោយបរិយាប័ន្ន គឺផ្តោតសំខាន់ទៅលើវដ្តនៃការគ្រប់គ្រងគ្រោះមហន្តរាយ ដែលបានកំណត់ក្នុងគោលការណ៍ណែនាំនេះ គឺសម្រាប់គ្រប់អ្នកពាក់ព័ន្ធធ្វើការងារគ្រប់គ្រងគ្រោះមហន្តរាយ យកធ្វើជាជំនួយស្មារតីពិនិត្យពិចារណាក្នុងការដាក់បញ្ចូលទស្សនយេនឌ័រប្រកបដោយបរិយាប័ន្នទៅក្នុងគោលនយោបាយផែនការ និងកម្មវិធីគ្រប់គ្រងគ្រោះមហន្តរាយ។

យើងខ្ញុំមានក្តីសង្ឃឹមថា គោលការណ៍ណែនាំការបញ្ជ្រាបយេនឌ័រទៅក្នុងការគ្រប់គ្រងគ្រោះមហន្តរាយប្រកបដោយបរិយាប័ន្នគឺជាឧបករណ៍ជួយសម្របសម្រួលប្រមូលផ្តុំការចូលរួមធ្វើកិច្ចសហប្រតិបត្តិការលើការគ្រប់គ្រងនិងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយឱ្យកាន់តែមានប្រសិទ្ធភាព។

ខ្ញុំសូមឆ្លៀតយកឱកាសនេះក្នុងនាមគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួង ស្ថាប័ន អង្គការជាតិ និងអន្តរជាតិ និងអ្នកពាក់ព័ន្ធទាំងអស់ដែលបានចូលរួមចំណែកធ្វើឱ្យគោលការណ៍ណែនាំការបញ្ជ្រាបយេនឌ័រក្នុងការគ្រប់គ្រងគ្រោះមហន្តរាយប្រកបដោយបរិយាប័ន្នបានសម្រេច ដាក់ចេញប្រើប្រាស់ស្របតាមតម្រូវការជាក់ស្តែង។

ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២១

**គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ**

**អនុប្រធានទី១**

# គោលការណ៍ណែនាំការបញ្ជ្រាបយេនឌ័រ ក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ ប្រកបដោយបរិយាប័ន្ន


អារម្ភកថា

មាតិកា ទំព័រ

ពាក្យបំព្រួញ

ពាក្យគន្លឹះ

១. សេចក្តីផ្តើម ១

២. គោលការណ៍ណែនាំ ២

៣.ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ ២

៤. ការបញ្ជ្រាបយេនឌ័រក្នុងវដ្តនៃការគ្រប់គ្រងគ្រោះមហន្តរាយ ៥

៤.១.យេនឌ័រក្នុងការត្រៀមបង្ការ ការកាត់បន្ថយគ្រោះថ្នាក់ និងការត្រៀមរៀបចំ ១១

៤.១.១.ការត្រៀមបង្ការ ១២

៤.១.១.១.ការប៉ាន់ប្រមាណមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និងសមត្ថភាព ១២

៤.១.១.២.ការរៀបចំផែនការត្រៀមបម្រុង និងការធ្វើលំហាត់សាកល្បងឆ្លើយតបគ្រោះអាសន្ន ១៤

៤.១.២.ការកាត់បន្ថយគ្រោះថ្នាក់ ១៦

៤.១.២.១.ការប្រកាសឱ្យដឹងមុន និងបណ្តាញប្រាស្រ័យទាក់ទង ១៦

៤.១.២.២.ការបង្កើត និងគ្រប់គ្រងទីទួលសុវត្ថិភាព ១៧

៤.១.៣.ការត្រៀមរៀបចំ ១៨

៤.១.៣.១.ការប្រជុំត្រៀមបម្រុងមុនរដូវកើតមានគ្រោះមហន្តរាយ ១៨

៤.១.៣.២.ការបណ្តុះបណ្តាល និងអន្តរាគមន៍អភិវឌ្ឍន៍សមត្ថភាពផ្សេងៗ ១៩

៤.២.យេនឌ័រក្នុងការឆ្លើយតបសង្គ្រោះបន្ទាន់ ២០

៤.២.១.ការសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធក្នុងគ្រាអាសន្ន ២០

៤.២.២.ការប៉ាន់ប្រមាណតម្រូវការក្នុងគ្រោះអាសន្ន ការប្រមូលទិន្នន័យ ការវិភាគ និងការធ្វើរបាយការណ៍ពីគ្រោះមហន្តរាយ ២១

៤.២.៣.ការផ្តល់ជំនួយសង្គ្រោះ ២៣

៤.២.៤.ប្រតិបត្តិការរុករក សង្គ្រោះ និងការជម្លៀស ២៤

៤.៣.យេនឌ័រក្នុងការស្តារឡើងវិញពីគ្រោះមហន្តរាយ ២៤

៤.៣.១.ការប៉ាន់ប្រមាណតម្រូវការក្រោយពេលគ្រោះមហន្តរាយ ២៥

៤.៣.២.កម្មវិធីស្តារឡើងវិញ ២៦

៥.ឧបសម្ព័ន្ធ៖ ឯកសារបន្ថែមសម្រាប់ការដាក់បញ្ចូលសមភាពយេនឌ័រប្រកបដោយបរិយាប័ន្នសង្គមក្នុងការស្តារឡើងវិញ ២៨

## ពាក្យបំព្រួញ

| | |
|---|---|
| AADMER | កិច្ចព្រមព្រៀងអាស៊ានស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងការឆ្លើយតបគ្រោះអាសន្ន |
| AAR | ការពិនិត្យឡើងវិញនូវសកម្មភាពបន្ទាប់ |
| ABU | សហភាពផ្សព្វផ្សាយអាស៊ីប៉ាស៊ីហ្វិក |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ADPC | មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) |
| CCCSP | ផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុកម្ពុជា |
| CEDAW | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងទៅនឹងស្ត្រីភេទ |
| CEDAW Committee | គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ |
| CSO | អង្គការសង្គមស៊ីវិល |
| CVA | ការវាយតម្លៃសមត្ថភាព និងភាពងាយរងគ្រោះ |
| DM Law | ច្បាប់គ្រប់គ្រងគ្រោះមហន្តរាយ |
| DRR | ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ |
| EPRP | ផែនការត្រៀមបង្ការ និងឆ្លើយតបគ្រោះអាសន្ន |
| GAATES | សម្ព័ន្ធសកលស្តីពីបច្ចេកវិទ្យាដែលងាយស្រួលប្រើប្រាស់ និងបរិស្ថាន |
| GBV | អំពើហិង្សាពាក់ព័ន្ធផ្នែកយេនឌ័រ |
| GCCC | គណៈកម្មាធិការការប្រែប្រួលអាកាសធាតុ និងយេនឌ័រ |
| GCCSP | ផែនការយុទ្ធសាស្ត្រយេនឌ័រ និងការប្រែប្រួលអាកាសធាតុ |
| GDP | ផលិតផលក្នុងស្រុកសរុប (ផសស) |
| GFDRR | មូលនិធិសកលសម្រាប់ការកាត់បន្ថយគ្រោះមហន្តរាយ និងការស្តារឡើងវិញ |

| | |
|---|---|
| GGCA | សម្ព័ន្ធភាពអាកាសធាតុជាសកល និងយេនឌ័រ |
| GR37 | អនុសាសន៍ទូទៅលេខ ៣៧ របស់គណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងនិងស្ត្រីភេទ |
| HRF | វេទិកាឆ្លើយតបមនុស្សធម៌ |
| HVCA | ការវាយតម្លៃមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និងសមត្ថភាព |
| IFRC | សហព័ន្ធអន្តរជាតិនៃសមាគមកាកបាទក្រហម និងអឌ្ឍចន្ទក្រហម |
| LGBTI | ក្រុមមនុស្សស្រឡាញ់ភេទដូចគ្នា (ស្រីស្រឡាញ់ស្រី ប្រុសស្រឡាញ់ប្រុស មនុស្សស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ អន្តរភេទ) |
| MISP | កញ្ចប់សេវាបឋមអប្បបរមា |
| MoWA | ក្រសួងកិច្ចការនារី |
| NAPDRR | ផែនការសកម្មភាពជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ |
| NCDM | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| PDNA | ការវាយតម្លៃតម្រូវការក្រោយគ្រោះមហន្តរាយ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SADDD | ទិន្នន័យលម្អិត ការបែងចែកតាមភេទ និងអាយុ |
| SDG | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNDRR | ការិយាល័យអង្គការសហប្រជាជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ |
| UNESCAP | គណៈកម្មការសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិប្រចាំនៅតំបន់អាស៊ីប៉ាស៊ីហ្វិក |
| UNFPA | មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន |
| UNICEF | មូលនិធិសហប្រជាជាតិដើម្បីកុមារ |
| USAID | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ |
| WASH | ទឹកស្អាត និងអនាម័យ |

## ពាក្យគន្លឹះ

| ពាក្យ | និយមន័យ |
|---|---|
| **ពិការភាព** | ពិការភាពជាទស្សនាទានដែលវិវដ្តមិនឈប់ឈរ និងបណ្តាលមកពីអន្តរកម្មរវាងជនមានកម្សោយ និងឧបសគ្គផ្នែកឥរិយាបថ និងបរិស្ថាន ដែលរាំងមិនឱ្យពួកគេចូលរួមពេញលេញ និងប្រកបដោយប្រសិទ្ធភាពក្នុងសង្គម ដោយស្មើភាពគ្នាជាមួយអ្នកដទៃ។ |
| **គ្រោះមហន្តរាយ** | ការរំខានធ្ងន់ធ្ងរនៃដំណើរការរបស់សហគមន៍ ឬសង្គមដែលធ្វើឱ្យមានការបាត់បង់ និងប៉ះពាល់ធ្ងន់ធ្ងរដល់មនុស្ស សម្ភារៈ សេដ្ឋកិច្ច ឬបរិស្ថាន ហើយកម្រិតនៃការប៉ះពាល់ហួសពីលទ្ធភាពរបស់សហគមន៍ ឬសង្គមដែលទទួលរងការប៉ះពាល់ក្នុងការប្រើប្រាស់លៃលកដោះស្រាយដោយធនធានខ្លួនឯង។ |
| **ការគ្រប់គ្រងគ្រោះមហន្តរាយ** | សកម្មភាពមួយចំនួន មុនពេល ក្នុងពេល និងក្រោយពេលគ្រោះមហន្តរាយ ដើម្បីថែរក្សាការត្រួតពិនិត្យតាមដានពីគ្រោះមហន្តរាយ និងផ្តល់ក្របខ័ណ្ឌការងារសម្រាប់ជួយដល់មនុស្សដែលស្ថិតក្នុងហានិភ័យ ឬសហគមន៍ណាមួយ ដើម្បីបញ្ចៀសកាត់បន្ថយជាអប្បបរមា ឬធ្វើឱ្យមានប្រក្រតីភាពឡើងវិញពីផលប៉ះពាល់នៃគ្រោះមហន្តរាយ។ |
| **ហានិភ័យគ្រោះមហន្តរាយ** | អានុភាពនៃការបាត់បង់ដោយគ្រោះមហន្តរាយលើអាយុជីវិត សុខភាព ជីវភាពរស់នៅ ទ្រព្យសម្បត្តិ និងសេវាកម្មនានា ដែលអាចកើតឡើងចំពោះសហគមន៍ និងសង្គមនៅពេលមួយក្នុងពេលអនាគត។ |
| **ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ** | ទស្សនាទាន និងការអនុវត្តតាមរយៈការខិតខំប្រឹងប្រែងជាប្រព័ន្ធ ដើម្បីវិភាគ និងគ្រប់គ្រងកត្តាដែលអាចកើតមានគ្រោះមហន្តរាយ រួមទាំងការកាត់បន្ថយកម្រិតគ្រោះថ្នាក់នៃមុខសញ្ញាគ្រោះថ្នាក់ ធ្វើឱ្យតិចនូវភាពងាយរងគ្រោះរបស់មនុស្ស និងទ្រព្យសម្បត្តិ របៀបគ្រប់គ្រងដីធ្លី បរិស្ថាន និងពង្រឹងការត្រៀមខ្លួនរៀបចំសម្រាប់ព្រឹត្តិការណ៍អាក្រក់នានា។ |
| **ប្រព័ន្ធប្រកាសឱ្យដឹងមុន** | សមត្ថភាពដែលតម្រូវឱ្យមានការបង្កើនសម្រាប់ប្រមូល និងផ្សព្វផ្សាយទាន់ពេលវេលា និងប្រកាសព័ត៌មានដែលមានន័យគ្រប់គ្រាន់ទៅដល់ក្រុមមនុស្ស សហគមន៍ និងស្ថាប័នដែលគំរាមកំហែងដោយមុខសញ្ញាគ្រោះថ្នាក់ ដើម្បីត្រៀមធ្វើឱ្យសមស្រប និងទាន់ពេលវេលាពីការកាត់បន្ថយលទ្ធភាពនៃការអន្តរាយ ឬបាត់បង់។ |

| | |
|---|---|
| **គ្រោះអាសន្ន** | ការគំរាមកំហែងដែលតម្រូវឱ្យមានសកម្មភាពបន្ទាន់ប្រកបដោយប្រសិទ្ធភាព ដែលអាចបញ្ចៀសនូវការរីកធំឡើងនៃព្រឹត្តិការណ៍ដែលឈានដល់គ្រោះមហន្តរាយ។ |
| **ការប្រឈម** | ទ្រព្យសម្បត្តិសំខាន់ៗប្រឈមនឹងហានិភ័យដូចជា ប្រជាជន បរិស្ថាន សេដ្ឋកិច្ច សំណង់អគារនៅក្នុងតំបន់រងផលប៉ះពាល់ដោយសារគ្រោះមហន្តរាយ។ |
| **យេនឌ័រ** | សំដៅលើតួនាទី ឥរិយាបថ សកម្មភាព និងគុណលក្ខណៈដែលសង្គមមួយនៅពេលណាមួយកំណត់ថាសមស្របសម្រាប់បុរស និងស្ត្រី។ ក្រៅពីគុណលក្ខណៈ និងឱកាសក្នុងសង្គមដែលពាក់ព័ន្ធនិងភាពជាបុរស និងភាពជាស្ត្រី និងទំនាក់ទំនងរវាងស្ត្រីនិងបុរស និងទំនាក់ទំនងរវាងក្មេងស្រី និងក្មេងប្រុស យេនឌ័រក៏សំដៅលើទំនាកទំនងរវាងស្ត្រី និងទំនាក់ទំនងរវាងបុរសផងដែរ។ គុណលក្ខណៈ ឱកាស និងទំនាក់ទំនងទាំងនេះត្រូវបានបង្កើតឡើងក្នុងសង្គម និងរៀនសូត្រតាមរយៈដំណើរការសង្គមនីយកម្ម។ គុណលក្ខណៈ ឱកាស និងទំនាក់ទំនងទាំងនេះមានភាពជាក់លាក់តាមបរិបទ/ពេលវេលា និងអាចកែប្រែបាន។ យេនឌ័រកំណត់ពីអ្វីដែលត្រូវបានរំពឹងទុកអនុញ្ញាត និងឱ្យតម្លៃលើស្ត្រី ឬបុរសម្នាក់ក្នុងបរិបទមួយ។ ក្នុងសង្គមភាគច្រើនមានភាពខុសគ្នា និងវិសមភាពរវាងស្ត្រី និងបុរស ក្នុងការទទួលខុសត្រូវដែលបានកំណត់ សកម្មភាពដែលធ្វើឡើងការទទួលបាន និងគ្រប់គ្រងធនធានក៏ដូចជាឱកាសធ្វើសេចក្តីសម្រេចចិត្ត។ យេនឌ័រគឺជាផ្នែកមួយនៃបរិបទសង្គមវប្បធម៌ទូលំទូលាយដូចលក្ខណៈវិនិច្ឆ័យសំខាន់ៗផ្សេងទៀតសម្រាប់ការវិភាគសង្គមវប្បធម៌ដែរ ដូចជាវណ្ណៈ ជាតិសាសន៍ កម្រិតភាពក្រីក្រ ក្រុមជាតិពន្ធុ ទំនោរផ្លូវភេទ អាយុ។ល។ |
| **ការវិភាគយេនឌ័រ** | ការពិនិត្យល្អិតល្អន់ថាតើភាពខុសគ្នានៃតួនាទីយេនឌ័រ សកម្មភាព តម្រូវការ ឱកាស និងសិទ្ធិ/សិទ្ធិទទួលបានបង្កផលប៉ះពាល់ដូចម្តេចលើបុរស ស្ត្រី ក្មេងស្រី និងក្មេងប្រុសក្នុងស្ថានភាព ឬបរិបទមួយចំនួន។ ការវិភាគយេនឌ័រពិនិត្យទំនាក់ទំនងរវាងមនុស្សប្រុស និងមនុស្សស្រី ព្រមទាំងការទទួលបាន និងការគ្រប់គ្រងធនធាន និងបញ្ហាប្រឈមរបស់ពួកគេ។ ការវិភាគយេនឌ័រគួរត្រូវបានដាក់បញ្ចូលក្នុងការវាយតម្លៃ ឬការវិភាគស្ថានភាពគ្រប់វិស័យដើម្បីធានាថាអយុត្តិធម៌ និងវិសមភាពផ្អែកតាមយេនឌ័រមិនកាន់តែរីកធំឡើងដោយសារអន្តរាគមន៍ពាក់ព័ន្ធ និងប្រសិនបើអាចលើកកម្ពស់សមភាព និងយុត្តិធម៌ក្នុងទំនាក់ទំនងយេនឌ័រ។ |
| **សមភាពយេនឌ័រ** | សិទ្ធិ ការទទួលខុសត្រូវ និងឱកាសស្មើភាពរវាងស្ត្រី និងបុរស នឹងរវាងក្មេងស្រី និងក្មេងប្រុស។ សមភាពមិនមានន័យថាស្ត្រី និងបុរស នឹងមានលក្ខណៈ |

| | |
|---|---|
| | ដូចគ្នានោះទេ ប៉ុន្តែសំដៅលើថា សិទ្ធិ ការទទួលខុសត្រូវ និងឱកាសរបស់ស្ត្រី និងបុរស នឹងមិនអាស្រ័យលើថាតើពួកគេកើតមកមានភេទប្រុស ឬភេទស្រី នោះទេ។ សមភាពយេនឌ័រមានន័យថា ផលប្រយោជន៍ តម្រូវការ និងអាទិភាពរបស់ស្ត្រី និងបុរសត្រូវបានលើកមកពិចារណា ដោយកត់សម្គាល់ពីលក្ខណៈចម្រុះនៃក្រុមស្ត្រី និងក្រុមបុរស។ សមភាពយេនឌ័រមិនមែនជាបញ្ហារបស់ស្ត្រីតែម្ខាងឡើយ ប៉ុន្តែបុរស និងស្ត្រីគួរពាក់ព័ន្ធនិងចូលរួមពេញឱ្យបានពេញលេញ។ សមភាពរវាងស្ត្រី និងបុរសត្រូវបានចាត់ទុកជាបញ្ហាសិទ្ធិមនុស្ស និងជាបុរេលក្ខខណ្ឌ និងសូចនាករសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពដែលផ្តោតការយកចិត្តទុកដាក់លើមនុស្សផងដែរ។<br>សមភាពយេនឌ័ររួមបញ្ចូលទាំង សមភាពផ្លូវការ (សមភាពតាមផ្លូវច្បាប់៖ ការប្រព្រឹត្តដូចគ្នាចំពោះបុរស និងស្ត្រី) និងសមភាពជាក់លាក់ (សមភាពជាក់ស្តែង៖ សមភាពនៃលទ្ធផលជាក់ស្តែងសម្រាប់ស្ត្រី និងបុរស)។ |
| **សមធម៌យេនឌ័រ** | ក្នុងអង្គការសហប្រជាជាតិគេនិយមប្រើពាក្យ "សមភាពយេនឌ័រ" ជាង "សមធម៌យេនឌ័រ"។ សមធម៌យេនឌ័របញ្ជាក់ពីធាតុផ្សំមួយនៃការបកស្រាយយុត្តិធម៌សង្គមដែលជាទូទៅផ្អែកលើប្រពៃណី ទំនៀមទម្លាប់ សាសនា ឬវប្បធម៌ ដែលជាញឹកញាប់បង្កអន្តរាយដល់ស្ត្រី។ ការប្រើប្រាស់សមធម៌ក្នុងការលើកកម្ពស់ស្ត្រីត្រូវបានកំណត់ថាមិនអាចទទួលយកបាន។ សន្និសីទទីក្រុងប៉េកាំង ឆ្នាំ ១៩៩៥ បានសម្រេចប្រើប្រាស់ពាក្យ សមភាព។ ក្រោយមកទៀតពាក្យ "សមភាព" ត្រូវបានអនុម័តដោយគណៈកម្មាធិការ CEDAW ក្នុងអនុសាសន៍ទូទៅលេខ ២៨ ដែលលើកឡើងថា "រដ្ឋភាគីត្រូវបានអំពាវនាវឱ្យប្រើប្រាស់តែទស្សនាទាននៃសមភាពរបស់ស្ត្រី និងបុរស ឬសមភាពយេនឌ័រតែប៉ុណ្ណោះ និងមិនត្រូវប្រើប្រាស់ទស្សនាទាននៃសមធម៌យេនឌ័រក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្រោមអនុសញ្ញានេះឡើយ។ ទស្សនាទានសមធម៌យេនឌ័រត្រូវបានប្រើប្រាស់ក្នុងយុត្តាធិការមួយចំនួនដើម្បីសំដៅលើការប្រព្រឹត្តដោយយុត្តិធម៌ចំពោះស្ត្រីនិងបុរសទៅតាមតម្រូវការរបស់យុត្តាធិការទាំងនោះ។ ចំណុចនេះអាចរួមមានការប្រព្រឹត្តចំពោះដោយស្មើភាព ឬការប្រព្រឹត្តចំពោះដែលផ្សេងពីនេះ ប៉ុន្តែត្រូវបានចាត់ទុកថាសមមូលពាក់ព័ន្ធនិងសិទ្ធិ អត្ថប្រយោជន៍ កាតព្វកិច្ច និងឱកាស"។ |
| **ការបញ្ជ្រាបយេនឌ័រ** | ការបញ្ជ្រាបយេនឌ័រជាអភិក្រមដែលត្រូវបានប្រើប្រាស់ក្នុងប្រព័ន្ធ អង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិ សម្រាប់ការសម្រេចបានវឌ្ឍនភាពនៃសិទ្ធិរបស់ស្ត្រី និងក្មេងស្រី ក្នុងនាមជាសំណុំរងនៃសិទ្ធិមនុស្សដែលអង្គការសហប្រជាជាតិប្តេជ្ញាសម្រេចឱ្យបាន។ ការបញ្ជ្រាបយេនឌ័រមិនមែនជាគោលដៅ |

| | |
|---|---|
| | ឬវត្ថុបំណងឡើយ ប៉ុន្តែជាយុទ្ធសាស្ត្រសម្រាប់ការអនុវត្តសមភាពកាន់តែប្រសើរសម្រាប់ស្ត្រី និងក្មេងស្រី ធៀបនឹងបុរស និងក្មេងប្រុស។ ការបញ្ជ្រាបទស្សនយេនឌ័រ ជាដំណើរការវាយតម្លៃផលវិបាកនៃសកម្មភាពដែលបានគ្រោងឡើងលើស្ត្រី និងបុរស ដូចជា ច្បាប់ គោលនយោបាយ ឬកម្មវិធីនៅគ្រប់ផ្នែកនិងគ្រប់កម្រិត។ ការបញ្ជ្រាបយេនឌ័រជាវិធីមួយក្នុងការដាក់បញ្ចូលការព្រួយបារម្ភ និងបទពិសោធន៍របស់ស្ត្រី និងបុរសជាចំណុចស្នូលនៃការរៀបចំ ការអនុវត្ត ការពិនិត្យតាមដាន និងការវាយតម្លៃគោលនយោបាយ និងកម្មវិធីក្នុងវិស័យនយោបាយ សេដ្ឋកិច្ច និងសង្គមទាំងអស់ ដើម្បីឱ្យស្ត្រី និងបុរសទទួលបានអត្ថប្រយោជន៍ស្មើគ្នា និងមិនជំរុញឱ្យមានវិសមភាព។ គោលដៅចុងក្រោយនៃការបញ្ជ្រាបយេនឌ័រគឺការសម្រេចបានសមភាពយេនឌ័រ។ |
| **ឆ្លើយតបនឹងតម្រូវការយេនឌ័រ** | ការកំណត់ នឹងយល់ពីគម្លាត និងភាពលម្អៀងយេនឌ័រ រួចចាត់វិធានការ តាមរយៈបង្កើត និងអនុវត្តសកម្មភាពដើម្បីជម្នះបញ្ហាប្រឈម និងឧបសគ្គ ឈានទៅបង្កើនសមភាពយេនឌ័រ។ ធៀបនឹងពាក្យ "រំញោចយេនឌ័រ" ពាក្យ "ឆ្លើយតបនឹងតម្រូវការយេនឌ័រ" មានន័យលើសពី "ការមិនបង្កគ្រោះថ្នាក់" និងសំដៅលើ "ការធ្វើឱ្យល្អជាងមុន"។ |
| **រំញោចយេនឌ័រ** | ការយល់ និងការពិចារណាពីកត្តាសង្គមវប្បធម៌ដែលជាឫសគល់នៃការរើសអើងផ្អែកតាមយេនឌ័រ។ ក្នុងការអនុវត្ត រំញោចយេនឌ័រ សំដៅលើ "ការមិនបង្កគ្រោះថ្នាក់"។ |
| **មុខសញ្ញាគ្រោះថ្នាក់** | ព្រឹត្តិការណ៍មួយ បាតុភូតមួយ ឬសកម្មភាពរបស់មនុស្សដែលសក្តានុពលអាចធ្វើឱ្យខូចខាតជារូបវន្ត រួមមានការបាត់បង់អាយុជីវិត រងរបួស ខូចខាត និងបាត់បង់ទ្រព្យសម្បត្តិ រាំងស្ទះដល់សង្គម និងសេដ្ឋកិច្ច ឬខូចខាតបរិស្ថាន។ |
| **ការកាត់បន្ថយគ្រោះថ្នាក់** | វិធានការបែបរចនាសម្ព័ន្ធ និងបែបមិនមែនរចនាសម្ព័ន្ធដើម្បីទទួលធ្វើ ដើម្បីកម្រិតផលប៉ះពាល់មិនល្អនៃមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ ការខូចខាតបរិស្ថាន និងមុខសញ្ញាគ្រោះថ្នាក់ខាងបច្ចេកទេស។ ឧទាហរណ៍ វិធានការបែបរចនាសម្ព័ន្ធ ជាការងារវិស្វកម្ម ការកសាងទប់ទល់មុខសញ្ញាគ្រោះថ្នាក់ ចំណែកវិធានការបែបមិនមែនរចនាសម្ព័ន្ធ រួមមានការបង្កើនការយល់ដឹង ការអភិវឌ្ឍចំណេះដឹង គោលនយោបាយ ផែនការប្រើប្រាស់ដី និងគ្រប់គ្រងធនធាន និងការអនុវត្តប្រតិបត្តិការមធ្យោបាយនានា។ |
| **ការត្រៀមបង្ការ** | សកម្មភាពដើម្បីបញ្ចៀសទាំងស្រុងពីផលប៉ះពាល់បណ្តាលមកពីមុខសញ្ញាគ្រោះថ្នាក់ និងជាមធ្យោបាយ ដើម្បីបន្ថយជាអតិបរមាទាក់ទងនឹងគ្រោះមហន្តរាយនៃបរិស្ថានបច្ចេកវិទ្យា និងជីវសាស្ត្រ។ |

| | |
|---|---|
| **ការស្តារឡើងវិញ** | ដំណើរការក្រោយការសង្គ្រោះ និងការគាំទ្រការផ្លាស់ប្តូរទៅរកការកសាងឡើងវិញ និងការអភិវឌ្ឍយូរអង្វែង។ សកម្មភាពស្តារឡើងវិញមានប្រសិទ្ធភាពបំផុត ប្រសិនបើមានការប៉ាន់ប្រមាណ និងសម្របសម្រួលតាំងពីដំបូងក្នុងការឆ្លើយតបផ្នែកមនុស្សធម៌។ ការស្តារឡើងវិញពាក់ព័ន្ធនឹងការស្តារជាថ្មី និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធ របរចិញ្ចឹមជីវិត និងស្ថានភាពរស់នៅរបស់សហគមន៍រងផលប៉ះពាល់ដោយសារវិបត្តិ រួមទាំងកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយហានិភ័យដែលបង្កឡើងដោយវិបត្តិនោះ។ |
| **ភាពធន់** | សមត្ថភាពរបស់ប្រព័ន្ធ សហគមន៍ ឬសង្គមដែលប្រឈមមុខនឹងមុខសញ្ញាគ្រោះថ្នាក់ ដើម្បីទប់ទល់សម្របទៅតាម និងស្តារពីផលប៉ះពាល់នៃមុខសញ្ញាគ្រោះថ្នាក់ឱ្យបានទាន់ពេល និងមានប្រសិទ្ធភាពតាមរយៈសកម្មភាពនានាដោយសិក្សាពីគ្រោះមហន្តរាយពីអតីតកាលឱ្យមានការប្រុងប្រយ័ត្ននាពេលអនាគតនិងចាត់វិធានការឱ្យប្រសើរឡើងនូវការកាត់បន្ថយហានិភ័យ។ |
| **ការឆ្លើយតប** | ការផ្តល់សេវាកម្មសង្គ្រោះបន្ទាន់ និងជំនួយសាធារណៈនៅក្នុងពេល និងក្រោយពេលមានគ្រោះមហន្តរាយ ដើម្បីសង្គ្រោះជីវិត កាត់បន្ថយផលប៉ះពាល់លើសុខភាព ធានាសុវត្ថិភាពសាធារណៈ និងដោះស្រាយសេចក្តីត្រូវការសម្រាប់ការចិញ្ចឹមជីវិតជាមូលដ្ឋានរបស់ប្រជាជនដែលទទួលរងផលប៉ះពាល់។ |
| **ហានិភ័យ** | ភាពដែលអាចកើតមាននូវផលវិបាក ការធ្វើទុក្ខទោស ឬការបាត់បង់ដែលបានរំពឹងទុក (ស្លាប់ របួស ទ្រព្យសម្បត្តិ ជីវភាព សកម្មភាពសេដ្ឋកិច្ចត្រូវបានរំខាន ឬបរិស្ថានត្រូវបានខូចខាត) ដែលបណ្តាលមកពីអន្តរកម្មរវាងមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ ឬមនុស្ស ទៅនឹងភាពងាយរងគ្រោះ។ |
| **បរិយាប័ន្នសង្គម** | ដំណើរការនៃការបង្កើនលក្ខខណ្ឌនៃការចូលរួមក្នុងសង្គម ជាពិសេសសម្រាប់ជនដែលជួបការលំបាក តាមរយៈការបង្កើនឱកាស ការទទួលបានធនធាន សំឡេង និងការគោរពសិទ្ធិ។ |
| **ភាពងាយរងគ្រោះ** | លក្ខខណ្ឌដែលកំណត់ដោយកត្តារូបវន្ត សង្គម សេដ្ឋកិច្ច និងបរិស្ថាន ឬជាដំណើរការដែលបង្កើនភាពចុះខ្សោយរបស់សហគមន៍ ទៅនឹងផលប៉ះពាល់នៃមុខសញ្ញាគ្រោះថ្នាក់។ |

# ១.សេចក្តីផ្តើម

កម្ពុជាជាប្រទេសមួយក្នុងចំណោមបណ្តាប្រទេសនៅជុំវិញពិភពលោក ដែលប្រឈមទៅនឹងផលប៉ះពាល់នៃគ្រោះមហន្តរាយ ដូចជា ទឹកជំនន់ ភាពរាំងស្ងួត និងខ្យល់ព្យុះ (ខ្យល់កន្ត្រាក់) ហើយផលប៉ះពាល់មានកម្រិតខុសគ្នានៅទូទាំងប្រទេស។ ទឹកជំនន់ និងភាពរាំងស្ងួត ជាមុខសញ្ញាគ្រោះថ្នាក់ដែលកើតឡើងញឹកញាប់ក៏បណ្តាលមកពីការប្រែប្រួលអាកាសធាតុផងដែរ បង្កឲ្យមានការខាតបង់ ការខូចខាតច្រើន និងប៉ះពាល់ដល់អាយុជីវិតមនុស្ស សត្វជាដើមនៅកម្ពុជា។

គ្រោះមហន្តរាយបង្កផលប៉ះពាល់វិជ្ជមានខ្លាំងទៅលើប្រជាជនដែលខ្វះលទ្ធភាពគ្រប់គ្រាន់ និងរស់នៅតំបន់ជនបទដាច់ស្រយាល ហើយយេនឌ័រ និងកត្តាសង្គមផ្សេងទៀត ដូចជាស្ថានភាពសេដ្ឋកិច្ចនិងពិការភាព ក៏ទទួលឥទ្ធិពលផងដែរ។គ្រោះមហន្តរាយបង្កផលប៉ះពាល់ទៅលើសហគមន៍ទាំងមូលក៏ពិតមែន ប៉ុន្តែវាក៏បង្កផលប៉ះពាល់ខុសគ្នារវៀងបុរស និងស្ត្រី ដោយសារភាពខុសគ្នានៃតួនាទីក្នុងសង្គមរបស់បុរស និងស្ត្រី និងការបាត់បង់ឱកាសក្នុងសង្គមសេដ្ឋកិច្ចដែលជាបញ្ហាប្រឈមរបស់ស្ត្រី។ ស្ត្រី និងក្មេងស្រីងាយទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរក្នុងពេលមានគ្រោះមហន្តរាយ ខណៈដែលភាពងាយរងគ្រោះរបស់ពួកគេរងឥទ្ធិពលពីកត្តាផ្សេងទៀត ដូចជា អាយុ ពិការភាព ស្ថានភាពសេដ្ឋកិច្ច និងទំនោរផ្លូវភេទ។

ក្រោយពេលគ្រោះមហន្តរាយ អាយុកាលមធ្យមសង្ឃឹមរស់របស់ស្ត្រីងាយនឹងថយចុះ ហើយស្ត្រីងាយបាត់បង់ការងារ និងទ្រព្យសម្បត្តិ ជាងបុរស។ តាមទំនៀមទម្លាប់ ជាញឹកញាប់ស្ត្រីជួបឧបសគ្គក្នុងការទទួលបានគណនីធនាគារហិរញ្ញវត្ថុ និងការងារក្នុងការស្តារឡើងវិញពីគ្រោះមហន្តរាយ។ គ្រួសារដែលមានមេគ្រួសារស្ត្រី ចាស់ជរា បុរសពិការ និងអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរជាងគេ ដោយពួកគាត់មិនសូវមានទ្រព្យសម្បត្តិ ឬថវិកាសន្សំសម្រាប់ទ្រទ្រង់ជីវភាព។ នៅទូទាំងសកលលោក និងនៅក្នុងប្រទេសកម្ពុជា យេនឌ័រ និងវិសមភាពសង្គមផ្សេងទៀតក៏ជះឥទ្ធិពលលើភាពងាយរងគ្រោះដោយសារគ្រោះមហន្តរាយ និងភាពធន់ផ្នែកសង្គមសេដ្ឋកិច្ច។

ការដាក់បញ្ចូលទស្សនៈយេនឌ័រក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ ជាកិច្ចការដ៏សំខាន់ក្នុងការដោះស្រាយសមត្ថភាព សិទ្ធ និងតម្រូវការយេនឌ័រ។ គោលនយោបាយ ផែនការ និងកម្មវិធីគ្រប់គ្រងគ្រោះមហន្តរាយត្រូវពិចារណាពីផលប៉ះពាល់ផ្នែកយេនឌ័រដោយសារគ្រោះមហន្តរាយ និងវិសមភាពយេនឌ័រ។ ក្រៅពីនេះវិធានការគាំទ្រភាពធន់ផ្នែកសង្គមសេដ្ឋកិច្ច និងការចូលរួមរបស់ស្ត្រីនៅគ្រប់ដំណាក់កាលនៃការគ្រប់គ្រងគ្រោះមហន្តរាយ នឹងដោះស្រាយឬសគល់នៃភាពងាយរងគ្រោះរបស់ស្ត្រី និងផ្តល់ឱកាសឱ្យស្ត្រីប្រើប្រាស់សិទ្ធទៅតាមភាពខ្លាំង និងសមត្ថភាពរបស់ពួកគេ ចំណុចនេះមិនត្រឹមតែលើកកម្ពស់សមភាពយេនឌ័រប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើនលទ្ធផលដែលកាន់តែមានប្រសិទ្ធភាពសម្រាប់អ្នកពាក់ព័ន្ធទាំងអស់ និងត្រៀមខ្លួនតាមសហគមន៍ក្នុងការបន្សាំទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនាពេលអនាគតទៀតផង។ នៅពេលមានការពិចារណាពីផលប៉ះពាល់ផ្នែកយេនឌ័រដោយសារគ្រោះមហន្តរាយ កម្មវិធីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនឹងអាចបង្កើត ដោយអនុវត្តតាមគោលនយោបាយ ផែនការត្រៀមបម្រុង និងកម្មវិធីដែលជំរុញការស្តារឡើងវិញពីគ្រោះមហន្តរាយប្រកបដោយសមធម៌ និងប្រសិទ្ធភាព។

ការប្តេជ្ញាចិត្តរបស់កម្ពុជាក្រោមរបៀបវារៈឆ្នាំ ២០៣០ ក្នុងការ "មិនទុកនរណាម្នាក់ចោល" និងប្រយុទ្ធប្រឆាំងការរើសអើង និងវិសមភាពដែលបង្កផលប៉ះពាល់លើក្រុមជួបការលំបាកក្នុងសង្គម ដែលតម្រូវឱ្យយកចិត្តទុកដាក់លើតម្រូវការរបស់ស្ត្រី កុមារ ចាស់ជរា មានជនពិការភាព និងជនបាត់បង់លទ្ធភាពពលកម្មក្នុងការឆ្លើយតបគ្រោះមហន្តរាយហើយយេនឌ័រ និងសមធម៌យេនឌ័រ គឺជាគោលការណ៍ដ៏សំខាន់ ដែលត្រូវឱ្យមានការបញ្ជ្រាបយេនឌ័រក្នុងការគ្រប់គ្រងគ្រោះមហន្តរាយប្រកបដោយបរិយាប័ន្ន។

## ២.គោលការណ៍ណែនាំ

គោលការណ៍ណែនាំនេះត្រូវបានបង្កើតឡើងតាមតម្រូវការចាំបាច់នៃក្រុមជនងាយរងគ្រោះសម្រាប់អ្នកអនុវត្តន៍ និងអ្នកតាក់តែងគោលនយោបាយប្រើប្រាស់ពីការបញ្ជ្រាបយេនឌ័រក្នុងការគ្រប់គ្រងគ្រោះមហន្តរាយកនៅព្រះរាជាណាចក្រកម្ពុជា។ គោលការណ៍ណែនាំនេះមានគោលបំណងជួយឱ្យតួអង្គទាំងនេះយកទៅប្រើប្រាស់ និងបានយល់ដឹងពីផលប៉ះពាល់ផ្នែកយេនឌ័រដោយសារគ្រោះមហន្តរាយ ផ្តល់ការណែនាំ និងការអនុវត្តស្តីពីការកាត់បន្ថយផលប៉ះពាល់ ការដាក់បញ្ចូលទស្សនយេនឌ័រប្រកបដោយបរិយាប័ន្នសង្គមទៅក្នុងគោលនយោបាយ ផែនការ និងកម្មវិធីគ្រប់គ្រងគ្រោះមហន្តរាយ ដោយគ្របដណ្តប់លើការដាក់បញ្ចូលយេនឌ័រប្រកបដោយបរិយាប័ន្នសង្គមក្នុងវដ្តនៃការគ្រប់គ្រងគ្រោះមហន្តរាយទាំងមូលដូចជា ការត្រៀមបង្ការ ការកាត់បន្ថយគ្រោះថ្នាក់ ការត្រៀមរៀបចំ ការឆ្លើយតបសង្គ្រោះបន្ទាន់ និងការស្តារឡើងវិញ ហើយដើម្បីស្វែងយល់ពីសារៈសំខាន់នៃការបញ្ជ្រាបយេនឌ័រប្រកបដោយបរិយាប័ន្ន ដោយមានតំណភ្ជាប់ឯកសារពីអង្គការសហប្រជាជាតិ និងទីភ្នាក់ងារឯកទេសគ្រប់គ្រងគ្រោះមហន្តរាយសម្រាប់អំណានបន្ថែម។

## ៣.ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ

រាជរដ្ឋាភិបាលកម្ពុជាមានច្បាប់ យុទ្ធសាស្ត្រចតុកោណ គោលនយោបាយ ក្របខ័ណ្ឌការងារ និងផែនការជាច្រើនសម្រាប់លើកកម្ពស់សមភាពយេនឌ័រ ដែលរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងពីសិទ្ធិស្មើភាពរវាងបុរស និងស្ត្រីនៅចំពោះមុខច្បាប់ និងហាមឃាត់ការរើសអើងស្ត្រីក្រោមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិកម្ពុជា ២០១៩-២០២៣។ ក្រសួងកិច្ចការនារី បាននឹងបញ្ជ្រាបយេនឌ័រក្នុងគ្រប់វិស័យ និងកម្មវិធីអភិវឌ្ឍទាំងអស់ដោយផ្តោតសំខាន់លើការគាំទ្ររបរចិញ្ចឹមជីវិត និងសមត្ថភាពរបស់ស្ត្រីមានពិការភាព និងស្ត្រីជនជាតិដើមភាគតិច។ ការអនុវត្តយុទ្ធសាស្ត្រស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងគ្រោះមហន្តរាយ និងការអភិវឌ្ឍបៃតង គឺជាសកម្មភាពអាទិភាពផ្តោតលើការអភិវឌ្ឍធនធានមនុស្ស ដែលកំណត់យកសមភាពយេនឌ័រ និងកិច្ចការពារសង្គមផ្តោតជាចំណុចសំខាន់។ វិធានការរបស់រាជរដ្ឋាភិបាលកម្ពុជា រួមមានការបង្កើនការចូលរួមរបស់ស្ត្រីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងការពង្រីកកម្មវិធីជំនួយសង្គម ផែនការនារីរតនៈទី៥(២០១៩-២០២៣) ដែលត្រូវបានបង្កើតឡើងនិងអនុវត្តដោយក្រសួងកិច្ចការនារី ជាគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រនៅកម្ពុជា។ យុទ្ធសាស្ត្រទី៦ នៃផែនការ(យេនឌ័រ និងការប្រែប្រួលអាកាសធាតុ) ផ្តោតអាទិភាពលើការបញ្ជ្រាបយេនឌ័រ និងកម្មវិធីដែលគាំទ្រស្ត្រី ក្មេងស្រី និងក្រុមងាយរងគ្រោះផ្សេងទៀតក្នុងសង្គម ក្នុងការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ កំណើនបៃតង និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ចំណុចនេះរួមមបញ្ចូលការអនុវត្ត និងចែក

រំលែកការស្រាវជ្រាវបន្ថែមទៀត និងការគាំទ្រដល់អ្នកពាក់ព័ន្ធក្នុងការកសាងសមត្ថភាព និងការប្តេជ្ញាចិត្តរបស់ពួកគេក្នុងការអនុវត្តវិធានការគ្រប់គ្រងគ្រោះមហន្តរាយដែលមានរំញោចយេនឌ័រ។ ផែនការសមភាពយេនឌ័រ និងផែនការអភិវឌ្ឍរបស់រាជរដ្ឋាភិបាលកម្ពុជា មានបញ្ញត្តិស្តីពីការបញ្ជ្រាបយេនឌ័រ និងការពង្រីកបរិយាប័ន្នសង្គម ដូចជា ការបញ្ជ្រាប និងការពង្រីកក្នុងកម្មវិធីគ្រប់គ្រងគ្រោះមហន្តរាយ។

ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងផែនការសកម្មភាពជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០១៩-២០២៣ សម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា បានបង្កើនការយល់ដឹង និងភាពធន់របស់ក្រុមងាយរងគ្រោះក្នុងសង្គមទៅនឹងហានិភ័យគ្រោះមហន្តរាយ និងការបង្កើនលទ្ធភាពរបស់ក្រុមទាំងនេះក្នុងការប្រើប្រាស់ប្រព័ន្ធប្រកាសឱ្យដឹងមុន បានកំណត់ពីការចូលរួមជាតំណាងរបស់ក្រុមដែលងាយរងគ្រោះដោយសារផលប៉ះពាល់នៃគ្រោះមហន្តរាយ ដូចជា ស្ត្រី យុវជន កុមារ ចាស់ជរា និងជនមានពិការភាព ក្នុងវេទិកាជាតិស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ លទ្ធផលរំពឹងទុកនៃ ផែនការសកម្មភាពជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ចំពោះក្រុមពាក់ព័ន្ធក្នុងសង្គម រួមមានការបង្កើនភាពធន់នឹងគ្រោះមហន្តរាយ ស្ថានភាពរស់នៅសមរម្យក្នុងទីទួលសុវត្ថិភាព និងលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលបានសំណាញ់សុវត្ថិភាពសង្គម។ យុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់វិស័យសុខាភិបាលនៅកម្ពុជា ២០២០-២០២៤ គាំទ្រតម្រូវការរបស់ស្ត្រី និងក្មេងស្រីក្នុងគ្រោះមហន្តរាយ តាមរយៈការដាក់បញ្ចូលពេញលេញនូវកញ្ចប់សេវាបឋមអប្បបរមាក្នុងពេលមានវិបត្តិ (MISP) ដែលរៀបចំឡើងដោយក្រុមការងារអន្តរស្ថាប័នទទួលបន្ទុកសុខភាពបន្តពូជ (ដូចជាការផ្តល់សេវាសុខភាពមាតា សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ និងការទប់ស្កាត់ និងគ្រប់គ្រងផលវិបាកនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងគ្រោះអាសន្ន)។

ច្បាប់ស្តីពីការប្រែប្រួលអាកាសធាតុ បានកំណត់គ្រោះមហន្តរាយជាផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងដាក់បញ្ចូលទស្សនៈយេនឌ័រ និងបរិយាប័ន្នសង្គម។ ផែនការយុទ្ធសាស្ត្រយេនឌ័រ និងការប្រែប្រួលអាកាសធាតុ (GCCSP២០១៣-២០២៣)របស់គណៈកម្មាធិការដឹកនាំ និងសម្របសម្រួលការងារយេនឌ័រ និងការប្រែប្រួលអាកាសធាតុ(GCCC) នៃក្រសួងកិច្ចការនារី គាំទ្រការបញ្ជ្រាបយេនឌ័រក្នុងការតាក់តែងគោលនយោបាយទាំងអស់ដែលពាក់ព័ន្ធនិងការប្រែប្រួលអាកាសធាតុ និងបានគូសបញ្ជាក់ពីការលើកកម្ពស់ការចូលរួមរបស់ស្ត្រី ការកសាងសមត្ថភាពស្តីពីយេនឌ័រ និងការរៀបចំថវិកាដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ។

ក្របខណ្ឌអន្តរជាតិ និងក្របខណ្ឌថ្នាក់តំបន់ ដែលមានរាជរដ្ឋាភិបាលកម្ពុជាជាភាគី ក៏បានគូសបញ្ជាក់ពីសារៈសំខាន់នៃសមភាពយេនឌ័រ និងបរិយាប័ន្នសង្គមសម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព និងសមធម៌ផងដែរ។ ក្របខណ្ឌសេនដាយស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០១៥-២០៣០ ចែងថា ៖

*"ស្ត្រី និងការចូលរួមរបស់ស្ត្រីដើរតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព និងការបង្កើត ការកៀរគរធនធាន និងការអនុវត្តគោលនយោបាយ ផែនការ និងកម្មវិធីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដែលមានរំញោចយេនឌ័រ។ ដូច្នេះ ចាំបាច់ត្រូវមានវិធានការគ្រប់គ្រាន់សម្រាប់កសាងសមត្ថភាព និងបង្កើនភាពអង់អាចរបស់*

*ស្ត្រីក្នុងការត្រៀមខ្លួន ក៏ដូចជាកសាងសមត្ថភាពរបស់ពួកគេសម្រាប់ការប្រកបរបរចិញ្ចឹមជីវិតផ្សេងទៀតក្នុងស្ថានភាពក្រោយគ្រោះមហន្តរាយ។*

ទន្ទឹមនឹងនេះបទដ្ឋាន និងក្របខណ្ឌអន្តរជាតិសម្រាប់ការសម្រេចបានសមភាពយេនឌ័រ និងលើកកម្ពស់សិទ្ធិរបស់ស្ត្រី ដូចជាអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) បានគូសបញ្ជាក់ពីសារៈសំខាន់នៃការផ្សារភ្ជាប់កិច្ចខិតខំប្រឹងប្រែងពង្រឹងសមភាពយេនឌ័រទៅនឹងការគ្រប់គ្រងគ្រោះមហន្តរាយ។ គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទនៃអង្គការសហប្រជាជាតិ (គណៈកម្មាធិការ CEDAW) បានដាក់ចេញអនុសាសន៍ទូទៅលេខ ៣៧ នៅឆ្នាំ ២០១៨ ដែលបានគូសបញ្ជាក់ពីកាតព្វកិច្ចរបស់រដ្ឋភាគីក្នុងការទប់ស្កាត់មិនឱ្យស្ត្រី និងក្មេងស្រីទទួលរងផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដោយសារគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយផលប៉ះពាល់ទាំងនេះ។

**តារាងពីការប្តេជ្ញាចិត្តផ្នែកយេនឌ័រក្នុងក្របខណ្ឌថ្នាក់តំបន់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយនៅតំបន់អាស៊ីប៉ាស៊ីហ្វិក**[1]

| ក្របខ័ណ្ឌកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក | ការប្តេជ្ញាចិត្តផ្នែកយេនឌ័រ |
|---|---|
| សេចក្តីប្រកាសទីក្រុងម៉ានីលឆ្នាំ ២០០៨ សម្រាប់សកម្មភាពជាសកលស្តីពីការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ | - ការបញ្ជ្រាបយេនឌ័រក្នុងដំណើរការអន្តរជាតិ និងដំណើរការថ្នាក់ជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ សម្រាប់ជាអាទិភាពថ្នាក់តំបន់។<br>- យុគភាពយេនឌ័រក្នុងការធ្វើសេចក្តីសម្រេចគ្រប់កម្រិត |
| របៀបវារៈទីក្រុងប៉េកាំងឆ្នាំ២០០៩សម្រាប់សកម្មភាពជាសកលស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដែលមានរំញោចយេនឌ័រ។ | - កំណត់គោលដៅ ៩ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ ដូចជា ការប្រមូល និងការត្រួតពិនិត្យទិន្នន័យដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ។ |
| សេចក្តីប្រកាសទីក្រុងញូវដេលី ឆ្នាំ ២០១៦ ស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ | - អភិក្រមផ្តោតការយកចិត្តទុកដាក់លើមនុស្សដែលលើកកម្ពស់ការចូលរួមប្រកបដោយអត្ថន័យ និងភាពជាតំណាងរបស់ស្ត្រី កុមារ យុវជននិងជនមានពិការភាព។ |
| សេចក្តីប្រកាស Ulaanbaatar ឆ្នាំ ២០១៨ | - ការចូលរួមពេញលេញ និងស្មើភាពរបស់ស្ត្រីក្នុងវដ្តនៃការគ្រប់គ្រងគ្រោះមហន្តរាយ។<br>- ជំរុញការចូលរួមប្រកបដោយអត្ថន័យ និងគាំទ្រភាពជាតំណាងរបស់ស្ត្រី យុវជន ចាស់ជរា និងជនមានពិការភាពក្នុងតួនាទីដឹកនាំការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ |

| | |
|---|---|
| ផែនការសកម្មភាព២០១៨-២០២០នៃផែនការតំបន់អាស៊ីសម្រាប់ការអនុវត្តក្របខណ្ឌសេនដាយសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ២០១៥-២០៣០។ | - អំពាវនាវឱ្យមានការលើកកម្ពស់ និងគាំទ្រសកម្មភាពកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដែលមានរំញោចយេនឌ័រនិងឆ្លើយតបនឹងតម្រូវការយេនឌ័រនៅថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន រួមទាំងលទ្ធភាពជាសកលក្នុងការទទួលបានសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ការទប់ស្កាត់ និងការឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ភាពដឹកនាំរបស់ស្ត្រី និងការចូលរួមប្រកបដោយអត្ថន័យរបស់យុវជន។ |
| កម្មវិធីការងារនៃកិច្ចព្រមព្រៀងអាស៊ានស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងការឆ្លើយតបគ្រោះអាសន្ន (AADMER) ២០២១-២០២៥។ | - អភិក្រមទូទាំងសង្គមសម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយ ដោយកត់សម្គាល់ពីតម្រូវការ និងតួនាទីសំខាន់ៗរបស់ក្រុមដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតដោយសារគ្រោះមហន្តរាយ។<br>- មានលទ្ធផលរំពឹងទុកស្តីពីការបង្កើនភាពអង់អាចរបស់ក្រុមងាយរងគ្រោះ ដូចជា ស្ត្រី និងក្មេងស្រី។<br>- បង្កើតក្រុមការងារបច្ចេកទេសផ្នែកកិច្ចការពារ យេនឌ័រ និងបរិយាប័ន្ន ដើម្បីពង្រឹងកិច្ចសហការអន្តរវិស័យស្តីពីបរិយាប័ន្នសង្គម។ |

ក្រៅពីនេះ ក្របខ័ណ្ឌអន្តរជាតិគូសបញ្ជាក់ពីភាពចាំបាច់នៃការពិនិត្យតាមដាន និងការរាយការណ៍ប្រកបដោយសនិទ្ធពលស្តីពីយេនឌ័រ និងបរិយាប័ន្នសង្គម ដោយផ្អែកតាមសូចនាករសមស្របក្នុងសកម្មភាពគ្រប់គ្រងគ្រោះមហន្តរាយ។ ដូច្នេះ ចាំបាច់ត្រូវមានវេទិកាគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ជាតិ ដើម្បីពិនិត្យតាមដាន និងរាយការណ៍ទៅវេទិកានយោបាយកម្រិតខ្ពស់សម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព មហាសន្និបាតអង្គការសហប្រជាជាតិ និងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម ដើម្បីសម្រួលដល់ការពិនិត្យតាមដាន និងការរាយការណ៍នៅថ្នាក់ជាតិ គោលដៅអភិវឌ្ឍប្រកបដោយចីរភាព។

## ៤.ការបញ្ជ្រាបយេនឌ័រក្នុងវដ្តនៃការគ្រប់គ្រងគ្រោះមហន្តរាយ

ការបញ្ជ្រាបសមភាពយេនឌ័រប្រកបដោយបរិយាប័ន្នសង្គម ក្នុងដំណាក់កាលនីមួយៗនៃវដ្តគ្រប់គ្រងគ្រោះមហន្តរាយ វដ្តនេះ(រូប១) បំបែកដំណើរការស្មុគស្មាញនៃការគ្រប់គ្រងគ្រោះមហន្តរាយជា ៣ ដំណាក់កាល ៖ ១-ដំណាក់កាលមុនពេលគ្រោះមហន្តរាយ គឺការត្រៀមបង្ការ ការកាត់បន្ថយគ្រោះថ្នាក់ និងការត្រៀមរៀបចំ ២-ដំណាក់កាលក្នុងពេលមានគ្រោះមហន្តរាយ គឺការឆ្លើយតបសង្គ្រោះបន្ទាន់ ៣-ដំណាក់កាលក្រោយពេលគ្រោះមហន្តរាយ គឺការស្តារឡើងវិញ។ដូច្នេះ ជំពូកនេះនឹងផ្តល់ការណែនាំសម្រាប់ការបញ្ជ្រាបយេនឌ័រប្រកបដោយបរិយាប័ន្នសង្គមនៅដំណាក់កាលនីមួយៗ។ ផ្នែកនីមួយៗមានបញ្ជីត្រួតពិនិត្យករណីសិក្សា និងឧបករណ៍សម្រាប់ការ បញ្ជ្រាបយេនឌ័រប្រកបដោយបរិយាប័ន្នសង្គមព្រមទាំងតំណភ្ជាប់ឯកសារបន្ថែម។




*រូប១ ៖ ដំណាក់កាលទាំង ៣ នៃវដ្តគ្រប់គ្រងគ្រោះមហន្តរាយ*

មានជំហានសំខាន់ៗជាច្រើនក្នុងការដាក់បញ្ចូលយេនឌ័រ និងបរិយាប័ន្នសង្គមក្នុងដំណាក់កាលទាំង ៣ នៃវដ្តគ្រប់គ្រងគ្រោះមហន្តរាយ ដូចជា សារៈសំខាន់នៃការកំណត់អត្តសញ្ញាណក្រុមដែលងាយរងគ្រោះបំផុតក្នុងសង្គម ការប្រមូលទិន្នន័យលម្អិត បែងចែកតាមភេទ អាយុ និងភាពផ្សេងៗ(SADDD) និងការពិនិត្យតាមដាន ការវាយតម្លៃដែលឆ្លើយតបនឹងតម្រូវការយេនឌ័រប្រកបដោយបរិយាប័ន្នសង្គម។ CamDi និង PRISMទី២ ជាប្រព័ន្ធគ្រប់គ្រងទិន្នន័យដែលមានស្រាប់ក្នុងប្រទេសកម្ពុជា[1] ផ្នែកនេះក៏នឹងលើកឡើងពីចំណុចអន្តរវិស័យទាំងនេះផងដែរ។

**តើនរណាខ្លះត្រូវបានកំណត់ជាក្រុមងាយរងគ្រោះក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ?**

ដើម្បីធានាថា “មិនទុកនរណាម្នាក់ចោល” ចាំបាច់ត្រូវកំណត់អត្តសញ្ញាណក្រុមក្នុងសង្គមដែលងាយរងគ្រោះដោយសារផលប៉ះពាល់នៃគ្រោះមហន្តរាយ។ ក្នុងបរិបទកម្ពុជា ផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ កំណត់ថា ក្រុមទាំងនេះរួមមានស្ត្រី កុមារ យុវជន ចាស់ជរា ជនមានពិការភាព ជាពិសេសសមាជិកក្រីក្រនៃក្រុមទាំងនេះ ក្រុមពាក់ព័ន្ធផ្សេងទៀតរួមមានជនជាតិភាគតិច អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ និងក្រុម LBGTI។ បុគ្គលម្នាក់អាចជាសមាជិកនៃក្រុមទាំងនេះ (បង្ហាញក្នុងរូប ២, ប្រអប់ ១) និងទទួលរងការលំបាកប្រសព្វគ្នា។

ប្រអប់ 1 ៖ ភាពងាយរងគ្រោះប្រសព្វគ្នា




ស្ត្រីដែលជាមេគ្រួសារ និងជនមានពិការភាពនៅកម្ពុជាងាយរងគ្រោះដោយសារភាពក្រីក្រ។ ទោះជាយ៉ាងណា ស្ត្រីពិការដែលជាមេគ្រួសារក្រីក្រ ប្រឈមនឹង*ភាពងាយរងគ្រោះប្រសព្វគ្នា។* ជាញឹកញាប់ ក្រុមទាំងនេះប្រឈមនឹងការរើសអើងដោយផ្ទាល់ និងដោយប្រយោលដែលធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់ពួកគេ ក្នុងការកសាងភាពធន់ផ្នែកសង្គមសេដ្ឋកិច្ច ការទទួលបានព័ត៌មានប្រកាសឱ្យដឹងមុន និងសេវាស្តារឡើងវិញពីគ្រោះមហន្តរាយ និងចូលរួម និងដឹកនាំកិច្ចខិតខំប្រឹងប្រែងគ្រប់គ្រងគ្រោះមហន្តរាយ។ ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងជាក់លាក់ ក្នុងការស្វែងយល់ពីភាពងាយរងគ្រោះប្រសព្វគ្នា ដើម្បីធានាការគ្រប់គ្រងគ្រោះមហន្តរាយ តាមបែបបរិយាប័ន្ន និងលទ្ធផលប្រកបដោយសមភាព។

*រូប២ ៖ ឧទាហរណ៍នៃភាពងាយរងគ្រោះប្រសព្វគ្នាដោយសារផលប៉ះពាល់នៃគ្រោះមហន្តរាយនៅកម្ពុជា*

កិច្ចខិតខំប្រឹងប្រែងជំរុញការគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជាឱ្យកាន់តែមានបរិយាប័ន្ន គួរលើកឡើងពីសមត្ថភាព និងតម្រូវការរបស់ក្រុមក្នុងសង្គមដែលងាយរងគ្រោះដោយសារផលប៉ះពាល់នៃគ្រោះមហន្តរាយ ដោយផ្អែកតាមទិន្នន័យពីបរិបទមូលដ្ឋាន (សូមមើលប្រអប់ ២)។

ប្រអប់២៖ ការលើកឡើងពីសមត្ថភាព និងតម្រូវការរបស់ក្រុមក្នុងសង្គមដែលងាយរងគ្រោះ ដោយសារផលប៉ះពាល់នៃគ្រោះមហន្តរាយ

- ផ្តល់ជំនួយមូលនិធិ និងអនុវត្តសកម្មភាពគ្រប់គ្រងគ្រោះមហន្តរាយ ដែលបង្កើនភាពធន់របស់ស្ត្រី និងក្រុមពាក់ព័ន្ធផ្សេងទៀតក្នុងសង្គម។
- ធានាការគាំទ្រពីបុរស និងអ្នកកាន់អំណាចបែបប្រពៃណីក្នុងសហគមន៍សម្រាប់សកម្មភាពគ្រប់គ្រងគ្រោះមហន្តរាយ ដែលលើកកម្ពស់សមភាពយេនឌ័រ និងបរិយាប័ន្នសង្គម។
- បង្កើនការចូលរួម និងភាពដឹកនាំរបស់ស្ត្រី និងក្រុមពាក់ព័ន្ធផ្សេងទៀតក្នុងសង្គម ក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅគ្រប់កម្រិតនៃការគ្រប់គ្រងគ្រោះមហន្តរាយ។
- ធានាថា ស្ថាប័នជាតិទទួលបន្ទុកយេនឌ័រ និងបរិយាប័ន្នសង្គម មានធនធាន និងសមត្ថភាពគ្រប់គ្រាន់ និងសហការជាមួយពួកគេលើការគ្រប់គ្រងគ្រោះមហន្តរាយ។

## ទិន្នន័យលម្អិតបែងចែកតាមភេទ អាយុ និងភាពផ្សេងៗ

ទិន្នន័យលម្អិតបែងចែកតាមភេទត្រូវបានប្រើប្រាស់សម្រាប់ការរាប់ និងពិនិត្យផលប៉ះពាល់នៃគ្រោះមហន្តរាយ ទៅតាមប្រភេទផ្សេងៗក្នុងសង្គម។ តាមរយៈការផ្តល់ចំណេះដឹងសំខាន់ៗស្តីពីផលប៉ះពាល់ផ្សេងៗក្នុងសង្គមដោយសារគ្រោះមហន្តរាយ ទិន្នន័យបែងចែកតាមភេទនឹងជួយដល់តួអង្គគ្រប់គ្រងគ្រោះមហន្តរាយ ក្នុងការរៀបចំជំនួយដែលឆ្លើយតបនឹងតម្រូវការរបស់ក្រុមងាយរងគ្រោះក្នុងសង្គម និងបង្កើនការចូលរួមរបស់ពួកគេ។ អនុសាសន៍ទូទៅលេខ ៣៧ ស្នើឱ្យមានការប្រមូល និងប្រើប្រាស់ "ទិន្នន័យបែងចែកតាមភេទ អាយុ ពិការភាព ជាតិពន្ធុ និងតំបន់។ ល្អបំផុតទិន្នន័យបែងចែក

តាមភេទគួររួមបញ្ចូលកត្តាសង្គមឱ្យបានច្រើន។ ក្នុងពេលរៀបរៀងឯកសារនេះទិន្នន័យលម្អិតបែងចែកតាមភេទ និងអាយុ កំពុងត្រូវបានប្រមូលតាមរយៈប្រព័ន្ធគ្រប់គ្រងទិន្នន័យ CamDi និង PRISMទី២។ ទន្ទឹមនឹងនេះ ផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០១៩-២០២៣ បានគូសបញ្ជាក់ពីសារៈសំខាន់ និងសកម្មភាពវិជ្ជមានឆ្ពោះទៅរកការប្រមូលទិន្នន័យបែងចែកតាមពិការភាព និងថវិការចំណូល/ទ្រព្យសម្បត្តិ។ ចំណុចសំខាន់គឺគេអាចបែងចែកពិការភាពជា ៦ ផ្នែក ៖ ការដើរ គំហើញ ការស្តាប់ ការស្គាល់/ដឹង ការថែទាំខ្លួនឯង និងទំនាក់ទំនង។ គេអាចប្រើកម្រងសំណួរធម្មតា ឬកម្រងសំណួរខ្លីស្តីពីពិការភាព ដើម្បីកំណត់ស្តង់ដារនៃការប្រមូលទិន្នន័យតាមរបៀបដែលផ្តោតសំខាន់លើបទពិសោធន៍របស់មនុស្ស ពាក់ព័ន្ធនឹងកម្រិតនៃការបំពេញមុខងារផ្ទាល់ខ្លួន អ្វីដែលសំខាន់គឺបុគ្គលគ្រប់រូបគួរមានជម្រើសក្នុងការបង្ហាញ ឬលាក់ទុកព័តមានស្តីពីលក្ខណៈផ្ទាល់ខ្លួន។

គួរប្រមូល SADDD តាមបែបបរិយាប័ន្ន និងគិតគូរពីវប្បធម៌។ ក្រោយការកំណត់អត្តសញ្ញាណក្រុមជាក់លាក់ក្នុងសង្គមជាក្រុមងាយរងគ្រោះក្នុងបរិបទគ្រោះមហន្តរាយ សមាជិកនៃសហគមន៍ទាំងនេះអាចត្រូវបានជ្រើសរើសឱ្យធ្វើជាអ្នកប្រមូលទិន្នន័យ និងអ្នកចូលរួមក្នុងការអង្កេត។សមាជិកនៃសហគមន៍ងាយរងគ្រោះដូចជា ក្រុមជាតិពន្ធុមួយចំនួនអាចមានភាពងាយស្រួលក្នុងការបង្ហាញព័ត៌មានដល់អ្នកប្រមូលទិន្នន័យដែលមកពីសហគមន៍តែមួយព្រោះពួកគេមានបទពិសោធន៍ ភាសា និងការយល់ដឹងផ្នែកវប្បធម៌ដូចគ្នា ដើម្បីធានាថាទិន្នន័យឆ្លុះបញ្ចាំងយ៉ាងសុក្រឹតពីបទពិសោធន៍របស់ស្ត្រី និងកុមារ គួរប្រមូលទិន្នន័យទាំងនេះនៅកម្រិតបុគ្គលជាជាងនៅកម្រិតគ្រួសារ។ អ្នកប្រមូលទិន្នន័យគួរគិតគូរពីបទដ្ឋានយេនឌ័រក្នុងមូលដ្ឋាន ដូចជាការដែលអ្នកប្រមូលទិន្នន័យជាបុរស និយាយតទល់ជាមួយស្ត្រីក្នុងកន្លែងឯកជន អាចជាទង្វើមិនសមស្រប។ អ្នកប្រមូលទិន្នន័យអាចលើកកម្ពស់ការចូលរួមប្រកបដោយសមភាពយេនឌ័រ តាមរយៈការរៀបចំការណាត់ជួបនៅតាមទីតាំង សមស្របសម្រាប់អ្នកចូលរួមទាំងអស់ ក្នុងពេលវេលាសមស្របទាំងសម្រាប់ស្ត្រី និងបុរស ខណៈដែលក្នុងបរិបទជាច្រើន ស្ត្រីអាចអាចនិយាយដោយសេរីនៅពេលគ្មានវត្តមានរបស់បុរស ត្រូវមានភាពប៉ិនប្រសប់ក្នុងការស្វែងរកការយល់ព្រមពីសមាជិកគ្រួសារជាបុរស ដោយមិនធ្វើឱ្យប៉ះពាល់ដល់ភាពឯកជន ការរក្សាការសម្ងាត់ និងសុវត្ថិភាពនៃទិន្នន័យដែលបានប្រមូល។ មិនគួរបញ្ចូលសំណួរពាក់ព័ន្ធនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងឧបករណ៍ប្រមូលទិន្នន័យឡើយ ហើយអ្នកប្រមូលទិន្នន័យគួរទទួលបានការបណ្តុះបណ្តាលសមស្របស្តីពីក្រមសីលធម៌ និងការពិចារណាពីសុវត្ថិភាពសម្រាប់ការស្រាវជ្រាវអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ក្នុងករណីដែលអ្នកចូលរួមបង្ហាញបទពិសោធន៍ទទួលរងអំពើហិង្សាទាក់ទងនឹងយេនឌ័រ អ្នកប្រមូលទិន្នន័យត្រូវទទួលបានការបំពាក់បំប៉ន និងការបណ្តុះបណ្តាលគ្រប់គ្រាន់ស្តីពីវិធីដែលមានសុវត្ថិភាពក្នុងការបញ្ជូនពួកគេទៅរកសេវាដែលមាន និងអាចទុកចិត្តបាន។ SADDD ជាឧបករណ៍ដ៏សំខាន់សម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយបែបបរិយាប័ន្ន ដែលត្រូវប្រមូលជាទៀងទាត់ និងយ៉ាងយកចិត្តទុកដាក់។

**ការពិនិត្យតាមដាន និងវាយតម្លៃដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ**

SADDD គូសបញ្ជាក់ពីផលប៉ះពាល់ខុសៗគ្នានៃគ្រោះមហន្តរាយ ដូច្នេះទិន្នន័យប្រភេទនេះជាបុរេលក្ខខ័ណ្ឌដ៏សំខាន់មួយសម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃបែបបរិយាប័ន្ន។ ដើម្បីច្បាម

យកលទ្ធផលប្រែប្រួលសម្រាប់ក្រុមផ្សេងៗក្នុងសង្គម គួរប្រមូល SADDD ក្នុងអំឡុងពេលដូចខាងក្រោម ៖

- ពេលត្រៀមខ្លួនបង្ការគ្រោះមហន្តរាយ (ការវាយតម្លៃបឋមក្នុងអំឡុងពេលប្រក្រតី)។
- ពេលវាយតម្លៃតម្រូវការក្នុងគ្រោះអាសន្ន (ការឆ្លើយតបគ្រោះមហន្តរាយ)។
- ពេលចាប់ផ្តើមវិធានការគ្រប់គ្រងគ្រោះមហន្តរាយ ដោយប្រើប្រាស់ការវាយតម្លៃតម្រូវការក្រោយពេលគ្រោះមហន្តរាយ (PDNA) ឬការវាយតម្លៃសមត្ថភាព និងភាពងាយរងគ្រោះ (CVA) (ដើម្បីបង្កើត "ទិន្នន័យដើមគ្រា")។
- ពេលអនុវត្តកម្មវិធីគ្រប់គ្រងគ្រោះមហន្តរាយ (ការឆ្លើយតបគ្រោះមហន្តរាយ និងការស្តារឡើងវិញ) ។

គេអាចប្រើប្រាស់ទិន្នន័យទាំងនេះដើម្បីបង្កើតទិន្នន័យដើមគ្រា និងមូលដ្ឋានទិន្នន័យនៅថ្នាក់មូលដ្ឋាន ថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ សម្រាប់ការពិនិត្យតាមដានផលប៉ះពាល់នៃគ្រោះមហន្តរាយលើក្រុមផ្សេងៗក្នុងសង្គម។ គេអាចប្រើប្រាស់ការវិភាគ SADDD ដើម្បីបង្កើតសារតានៃភាពងាយរងគ្រោះសម្រាប់សហគមន៍ផ្សេងៗ និងបង្កើតសូចនាករយេនឌ័រ និងបរិយាប័ន្នសង្គមសម្រាប់ការពិនិត្យ តាមដាន និងវាយតម្លៃ។

ប្រអប់ ៣ ផ្តល់គំរូបញ្ជីត្រួតពិនិត្យការពិនិត្យតាមដាន និងវាយតម្លៃដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ និងមានបរិយាប័ន្នសង្គម។

| |
|---|
| ប្រអប់៣ ៖ គំរូបញ្ជីត្រួតពិនិត្យការពិនិត្យតាមដាន និងវាយតម្លៃដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ ប្រកបដោយបរិយាប័ន្នសង្គម ៖<br>● ប្រមូលទិន្នន័យនៅកម្រិតបុគ្គល ជាជាងនៅកម្រិតគ្រួសារ។<br>● ប្រមូលទិន្នន័យលម្អិត បែងចែកតាមភេទ អាយុ ពិការភាព ជាតិពន្ធុ តំបន់ និងកត្តាសង្គមពាក់ព័ន្ធផ្សេងទៀត (ទោះបីជាបុគ្គលគ្រប់រូបមានសិទ្ធិបង្ហាញ ឬលាក់ទុកព័ត៌មានស្តីពីលក្ខណៈផ្ទាល់ខ្លួនក្តី)។<br>● ធានាដាក់បញ្ចូលស្ត្រី និងសមាជិកនៃក្រុមពាក់ព័ន្ធផ្សេងទៀតក្នុងសង្គម ក្នុងក្រុមអង្កេត។<br>● បណ្តុះបណ្តាលអ្នកប្រមូលទិន្នន័យ ស្តីពីវិធីដែលមានសុវត្ថិភាពក្នុងការបញ្ជូនជនរងគ្រោះដោយសារអំពើហិង្សាទាក់ទងនិងយេនឌ័រទៅរកសេវាដែលមាន និងអាចទុកចិត្តបាន។<br>● ធានាថា ស្ត្រី បុរស និងសមាជិកនៃក្រុមពាក់ព័ន្ធក្នុងសង្គម ត្រូវបានសម្ភាសន៍សម្រាប់ការវាយតម្លៃ ដូចជា ការរៀបចំការណាត់ជួបនៅទីតាំង និងពេលវេលាសមស្រប និងធ្វើការកែសម្រួលចាំបាច់ដើម្បីធានាភាពអាចចូលរួមបាន ( ការសម្ភាសន៍ជាភាសាផ្សេង)។<br>● បណ្តុះបណ្តាលក្រុមប្រមូលទិន្នន័យ និងក្រុមពិនិត្យតាមដាន និងវាយតម្លៃស្តីពីការវិភាគយេនឌ័រ។<br>● បង្កើតមូលដ្ឋានទិន្នន័យដើមគ្រានៅថ្នាក់មូលដ្ឋាន ថ្នាក់តំបន់ និងថ្នាក់ជាតិ និងបង្កើតសារតានៃភាពងាយរងគ្រោះសម្រាប់សហគមន៍ផ្សេងៗ។<br>● បង្កើត និងប្រើប្រាស់ទិន្នន័យដើមគ្រា និងសូចនាករពិនិត្យតាមដាន បែងចែកតាមភេទ អាយុ ពិការភាព ជាតិពន្ធុ តំបន់ និងកត្តាពាក់ព័ន្ធផ្សេងទៀតក្នុងសង្គម ដើម្បីពិនិត្យផលប៉ះពាល់នៃគ្រោះមហន្តរាយលើក្រុមទាំងអស់ក្នុងសង្គម។ |

សូចនាករពិនិត្យតាមដានដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ និងមានបរិយាប័ន្នសង្គមវាស់វែងការប្រែប្រួលទំនាក់ទំនងក្នុងសង្គមពីពេលមួយទៅពេលមួយ ដែលអាចបញ្ជាក់ពីបុព្វហេតុនៃលទ្ធផលខុសគ្នាសម្រាប់ក្រុមផ្សេងៗក្នុងសង្គម។ សូចនាករដើមគ្រាវាស់វែងស្ថានភាពនៃទំនាក់ទំនងសង្គមមុនពេលមានអន្តរាគមន៍ ចំណែកសូចនាករពិនិត្យតាមដាន វាស់វែងការប្រែប្រួលទំនាក់ទំនងក្នុងសង្គម មានសូចនាករក្នុងផ្នែក A វាស់វែងផលប៉ះពាល់ផ្សេងៗនៃគ្រោះមហន្តរាយទៅតាមប្រភេទផ្សេងៗក្នុងសង្គម គេអាចប្រើប្រាស់សូចនាករទាំងនេះដើម្បីវាយតម្លៃបរិយាប័ន្ននៃវិធានការឆ្លើយតបគ្រោះមហន្តរាយ និងវិធានការស្តារឡើងវិញ និងកំណត់អត្តសញ្ញាណក្រុមដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ ដែលអាចត្រូវការការគាំទ្របន្ថែម ប្រសិនបើមានគ្រោះមហន្តរាយកើតឡើងនាពេលអនាគត។ សូចនាករក្នុងផ្នែក B វាស់វែងការចូលរួមរបស់ស្ត្រីក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ និងអាចប្រើប្រាស់សម្រាប់ត្រួតពិនិត្យវឌ្ឍនភាពនៃការសម្រេចបានសមភាពយេនឌ័រក្នុងផ្នែកនេះ។

**តារាងនៃសូចនាករពិនិត្យតាមដាន និងសូចនាករដើមគ្រាដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ និងមានបរិយាប័ន្នសង្គម ក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ**

| សូចនាករដើមគ្រា | សូចនាករពិនិត្យតាមដាន |
|---|---|
| ផ្នែក A ៖ ផលប៉ះពាល់នៃគ្រោះមហន្តរាយ | |
| ប្រជាជនបែងចែកតាមភេទ និអាយុ រួមទាំងភាគរយនៃទារក យុវជន (ក្រោម ១៥ ឆ្នាំ) និងចាស់ជរា (អាយុលើស ៦៥ ឆ្នាំ)។ | ចំនួនប្រជាជនបាត់បង់ទីលំនៅក្នុងប្រទេស ក្រោយពេលគ្រោះមហន្តរាយ បែងចែកតាមភេទ អាយុ និងភាពផ្សេងៗ។ |
| ចំនួនប្រជាជនដែលជាសមាជិកក្រុមជួបការលំបាក បែងចែកតាមភេទ អាយុ និងនភាពផ្សេងៗ។ | ភាគរយអ្នកស្លាប់ និងរបួសដោយសារគ្រោះមហន្តរាយក្នុងចំណោមប្រជាជនជួបលំបាក បែងចែកតាមភេទ អាយុ និងភាពផ្សេងៗ។ |
| ផ្នែក B ៖ កត្តានយោបាយ និងកត្តាស្ថាប័នសម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយ | |
| ការចូលរួមរបស់ស្ត្រីក្នុងដំណើរការគ្រប់គ្រងគ្រោះមហន្តរាយ។ | ភាគរយនៃស្ត្រី ដែលចូលរួមក្នុងការឆ្លើយតបគ្រោះមហន្តរាយ ចំនួនប្រជាជនដែលពាក់ព័ន្ធក្នុងការងារស្តារឡើងវិញ បែងចែកតាមយេនឌ័រ អាយុ និងភាពផ្សេងៗ។ |
| ភាគរយនៃស្ត្រី និងបុរសក្នុងស្ថាប័នធ្វើសេចក្តីសម្រេចចិត្តក្នុងសហគមន៍។ | ភាគរយនៃស្ត្រីក្នុងគណៈកម្មាធិការមូលដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយ បែងចែកតាមយេនឌ័រ អាយុ និងភាពផ្សេងៗ។ |

ការរួមបញ្ចូល SADDD និងសូចនាករយេនឌ័រ និងបរិយាប័ន្នសង្គម មានសារៈសំខាន់ណាស់សម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃប្រកបដោយប្រសិទ្ធភាព និងសមធម៌។ ឧបករណ៍ទាំងនេះរំលេចផលប៉ះពាល់ផ្សេងៗក្នុងសង្គមដោយសារគ្រោះមហន្តរាយ និងវិធានការគ្រប់គ្រងគ្រោះមហន្តរាយ (ទាំងចេតនា និងអចេតនា) ដែលអាចឱ្យអ្នកអនុវត្តន៍កំណត់រកគម្លាតក្នុងបទបញ្ញត្តិសម្រាប់យកមកវិភាគក្នុងដំណើរការពិនិត្យឡើងវិញក្រោយបញ្ចប់សកម្មភាព (AAR) ។ គេអាចប្រើប្រាស់ដំណើរការនេះដើម្បីកំណត់ពីការអនុវត្តល្អបំផុត និងមេរៀនសម្រាប់គ្រោះមហន្តរាយនាពេលអនាគត ដើម្បីផ្តល់មូលដ្ឋានព័ត៌មានដល់ការចាត់វិធានការភ្លាមៗ ក្នុងការដោះស្រាយបញ្ហាវិសមភាពដែលលេចឡើងក្នុងការឆ្លើយតបគ្រោះមហន្តរាយ និងការផ្លាស់ប្តូរយូរអង្វែងលើការអនុវត្តក្នុងស្ថាប័ន។ ការពិនិត្យតាមដាន និងវាយតម្លៃដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ និងមានបរិយាប័ន្នសង្គមផ្សារភ្ជាប់ដំណាក់កាលស្តារឡើងវិញ ទៅនឹងដំណាក់កាលឆ្លើយតបនៃវដ្តគ្រប់គ្រងគ្រោះមហន្តរាយ។ ដំណើរការទាំងនេះនឹងផ្តល់មូលដ្ឋានព័ត៌មានសម្រាប់ការរៀបចំរបាយការណ៍វឌ្ឍនភាព គ្របខ័ណ្ឌសេនដាយ និងវេទិកានយោបាយកម្រិតខ្ពស់សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព (ក្នុងគោលដៅអភិវឌ្ឍប្រកបដោយចីរភាព) ដើម្បីបង្ហាញវឌ្ឍនភាពនៃសមភាពយេនឌ័រ និងបរិយាប័ន្នសង្គមក្នុងគោលនយោបាយ និងកម្មវិធីគ្រប់គ្រងគ្រោះមហន្តរាយ។

**បញ្ជីត្រួតពិនិត្យការប្រើប្រាស់ SADDD និងសូចនាករយេនឌ័រ និងបរិយាប័ន្នសង្គម ៖**

- ប្រមូល SADDD ដើម្បីបង្កើតទិន្នន័យដើមគ្រា និងមូលដ្ឋានទិន្នន័យថ្នាក់មូលដ្ឋាន ថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ។
- ប្រើប្រាស់ SADDD សម្រាប់ជួយដល់ការវិភាគយេនឌ័រ ដើម្បីផ្តល់ព័ត៌មានស្តីពី ៖
  - សារតានៃភាពងាយរងគ្រោះសម្រាប់សហគមន៍ផ្សេងៗ។
  - ការបង្កើត និងអនុវត្តគោលនយោបាយ និងកម្មវិធីគ្រប់គ្រងគ្រោះមហន្តរាយ។
- ប្រើប្រាស់ SADDD ដើម្បីបង្កើតសូចនាករយេនឌ័រ និងបរិយាប័ន្នសង្គម សម្រាប់ពិនិត្យតាមដានវឌ្ឍនភាពនៃការគ្រប់គ្រងគ្រោះមហន្តរាយតាមបែបបរិយាប័ន្ន។
- ផ្តល់ការកសាងសមត្ថភាពគ្រប់គ្រាន់ និងបែងចែកជំនួយមូលនិធិសម្រាប់ការប្រមូល ការគ្រប់គ្រង និងការប្រើប្រាស់ SADDD នៅថ្នាក់មូលដ្ឋាន ថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ។
- ប្រើប្រាស់ SADDD និងសូចនាករយេនឌ័រ និងបរិយាប័ន្នសង្គមដើម្បី ៖
  - វាយតម្លៃ និងបង្កើតគោលនយោបាយ និងកម្មវិធីគ្រប់គ្រងគ្រោះមហន្តរាយឡើងវិញ។
  - រាយការណ៍ពីវឌ្ឍនភាពទៅក្របខណ្ឌគ្រប់គ្រងគ្រោះមហន្តរាយ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ។

## ៤.១.យេនឌ័រក្នុងការត្រៀមបង្ការ ការកាត់បន្ថយគ្រោះថ្នាក់ និងការត្រៀមរៀបចំ

ការត្រៀមបង្កាការ កាត់បន្ថយគ្រោះថ្នាក់ និងការត្រៀមរៀបចំផ្តល់ឱកាសឱ្យសហគមន៍ធ្វើការវាយតម្លៃជាសមូហភាពលើភាពងាយរងគ្រោះ សមត្ថភាព និងការប្រឈមរបស់ពួកគេទៅនឹងហានិភ័យ។ ចំណុចនេះជួយឱ្យសហគមន៍ចាត់វិធានការជាជំហានៗក្នុងការទប់ស្កាត់កុំឱ្យគ្រោះថ្នាក់លើក្រុមងាយរងគ្រោះបំផុតក្នុងសង្គម។

ជំហានរួមមានការគាំទ្រលទ្ធភាពស្មើភាពក្នុងការទទួលបានធនធាន និងការលើកកម្ពស់ការចូលរួមពេញលេញ និងស្មើភាពរបស់មនុស្សគ្រប់រូបក្នុងការវាយតម្លៃសហគមន៍ ដែលមិនត្រឹមតែកសាងភាពធន់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើតសហគមន៍ដែលកាន់តែមានលក្ខណៈបរិយាប័ន្នទៀតផង។

<u>ប្រអប់៤ ៖ ការវិភាគយេនឌ័រ</u>

ការវិភាគយេនឌ័រជាមធ្យោបាយ ជាប្រព័ន្ធដើម្បីស្វែងយល់ពីទំនាក់ទំនង និងវិសមភាពយេនឌ័រក្នុងបរិបទមួយ។ ការវិភាគយេនឌ័រមិនត្រឹមតែពាក់ព័ន្ធនឹងស្ត្រីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពាក់ព័ន្ធនឹងតួនាទី និងទំនាក់ទំនងយេនឌ័រទៀតផង (ដូចជា បញ្ហាយេនឌ័រពាក់ព័ន្ធនឹងបុរស ដែលបង្កើនភាពងាយរងគ្រោះរបស់បុរស និងក្មេងប្រុស ឬផ្នត់គំនិតចំពោះស្ត្រីដែលរឹតត្បិតឱកាសរបស់ស្ត្រី)។ ការវិភាគយេនឌ័រអាចរួមមានការស្រាវជ្រាវបឋម និង/ឬការស្រាវជ្រាវបន្ទាប់បន្សំ។ សំណួរខាងក្រោមអាចជួយកំណត់រកបញ្ហា និងកត្តាដែលជះឥទ្ធិពលលើវិសមភាពយេនឌ័រក្នុងបរិបទមួយ ៖

- តើនរណាធ្វើអ្វី និងហេតុអ្វី?
- ដោយរបៀបណា? និងជាមួយអ្វី?
- តើនរណាកាន់កាប់អ្វី?
- តើនរណាទទួលខុសត្រូវលើអ្វី?
- តើនរណាមានសិទ្ធិទទួលបានអ្វី?
- តើនរណាគ្រប់គ្រងអ្វី?
- តើនរណាសម្រេចចិត្តលើអ្វី?
- តើនរណាទទួលបានអ្វី?
- តើនរណាចំណេញ? តើនរណាខាត?
- ហេតុអ្វី?

### ៤.១.១.ការត្រៀមបង្ការ

ត្រូវកសាងយុទ្ធសាស្ត្រដើម្បីរកអត្តសញ្ញាណការកាត់បន្ថយហានិភ័យ ត្រៀមបង្ការដើម្បីកាត់បន្ថយនូវការបាត់បង់ការខូចខាតទាំងឡាយដោយគ្រោះមហន្តរាយ តាមរយៈបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការ និងកម្មវិធីផ្សេងៗដោយបង្កើនចំណេះដឹង សមត្ថភាព អាទិភាព និងការយកចិត្តទុកដាក់ពីតម្រូវការរបស់ស្ត្រី។

#### ៤.១.១.១.ការប៉ាន់ប្រមាណមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និងសមត្ថភាព

ការប៉ាន់ប្រមាណមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និងសមត្ថភាព(HVCAs) ជាការប្រមូលព័ត៌មានស្តីពីមុខសញ្ញាគ្រោះថ្នាក់កន្លងមក ការគំរាមកំហែង និងភាពងាយរងគ្រោះបច្ចុប្បន្នក្នុងសហគមន៍ និងធនធានដែលមានក្នុងសហគមន៍ដើម្បីប្រឈមមុខជាមួយផលប៉ះពាល់នៃគ្រោះមហន្តរាយ។ ការវិភាគនេះប្រើប្រាស់វិធីសាស្ត្រវាយតម្លៃហានិភ័យបែបចូលរួមដែលសហគមន៍ប្រមូលទិន្នន័យ ដើម្បីទទួលបានព័ត៌មានសុក្រឹត និងបង្កើនការយល់ដឹង និងការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ។ ការវិភាគនេះជាគន្លឹះសម្រាប់ការបង្កើតការឆ្លើយតបដែលមិនទុកនរណាម្នាក់ចោល និងជាការកំណត់រកមុខសញ្ញាគ្រោះថ្នាក់ក្នុងសហគមន៍ ក្រុមផ្សេងៗ ដូចជា បុរស និងស្ត្រី កំណត់និងសន្មតខុសៗគ្នាលើហានិភ័យ ហើយក្រុមពាក់ព័ន្ធក្នុងសង្គមអាចទទួលរងហានិភ័យផ្សេងៗគ្នា។ ដូច្នេះការវាយតម្លៃមុខសញ្ញាគ្រោះថ្នាក់ក្នុងសហគមន៍ត្រូវរួមបញ្ចូលទស្សនចម្រុះ តាមរយៈការធានាភាពជាតំណាងសមស្របរបស់ក្រុមក្នុងសង្គមដែលរង

ផលប៉ះពាល់ធ្ងន់ធ្ងរដោយសារគ្រោះមហន្តរាយ។ ក្នុងការវាយតម្លៃភាពងាយរងគ្រោះសមាជិកសហគមន៍កំណត់ថាតើនរណាខ្លះ របរចិញ្ចឹមជីវិតអ្វីខ្លះ និងរចនាសម្ព័ន្ធណាខ្លះដែលងាយប្រឈមនឹងមុខសញ្ញាគ្រោះថ្នាក់ផ្សេងៗ។ ក្នុងការវាយតម្លៃសមត្ថភាព សមាជិកសហគមន៍កំណត់រកធនធានដែលពួកគេប្រើប្រាស់ដើម្បីប្រឈមជាមួយ និងស្តារឡើងវិញពីផលប៉ះពាល់វិជ្ជមាននៃគ្រោះមហន្តរាយ។ សមាជិកសហគមន៍នឹងផ្តល់ទស្សនៈយល់ឃើញចម្រុះទៅតាមអត្តសញ្ញាណ និងបទពិសោធន៍របស់ពួកគេ ដូច្នេះគួរធ្វើការវិភាគមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និងសមត្ថភាពតាមបែបចូលរួមប្រកបដោយបរិយាប័ន្នសង្គម។

ប្រអប់៥ ៖ បញ្ជីត្រួតពិនិត្យការវិភាគមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និងសមត្ថភាពប្រកបដោយបរិយាប័ន្ន

- លើកកម្ពស់ការចូលរួមដោយស្មើភាពរបស់ក្រុមទាំងអស់ក្នុងសង្គម ក្នុងការគូសផែនទីហានិភ័យ និងមុខសញ្ញាគ្រោះថ្នាក់។
- ជ្រើសរើសមនុស្សមួយក្រុមតូចដែលតំណាងឱ្យសមាជិកចម្រុះក្នុងសហគមន៍ ដើម្បីដើរសង្កេតមើលស្ថានភាពក្នុងសហគមន៍។
- បណ្តុះបណ្តាលសមាជិកចម្រុះក្នុងសហគមន៍ស្តីពីការវាយតម្លៃហានិភ័យ និងមុខសញ្ញាគ្រោះថ្នាក់។
- សម្ភាសន៍សមាជិកសហគមន៍ចម្រុះនៅពេលធ្វើបទសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធ ដូចជា ការធ្វើសំណាកសមាជិកសហគមន៍ពីទិន្នន័យបែងចែកតាមអាយុ យេនឌ័រ និងរបរចិញ្ចឹមជីវិត។
- រៀបចំវគ្គដាច់ដោយឡែកជាមួយស្ត្រី និងបុរស នៅពេលកំណត់រកការបែងចែកកម្លាំងពលកម្មផ្អែកតាមយេនឌ័រក្នុងប្រតិទិនតាមរដូវកាល ឬធ្វើការវិភាគរបរចិញ្ចឹមជីវិត។
- ធ្វើការបែងចែកជាប្រភេទក្នុងគ្រួសារនៅពេលគូសផែនទីធនធាន ដោយសួរថាតើសមាជិកគ្រួសារណាប្រើប្រាស់ និងគ្រប់គ្រងធនធានអ្វី។
- ផ្តោតការយកចិត្តទុកដាក់លើឌីណាមិកក្រុម ក្នុងក្រុមគោលដៅ និងលើកទឹកចិត្តអ្នកដែលមិនបានបញ្ចេញមតិ ឱ្យរួមចំណែក ឬពិគ្រោះជាមួយពួកគេដាច់ដោយឡែក (ប្រសិនបើសមស្រប)។
- កំណត់រកទិដ្ឋភាពនៃហានិភ័យដែលប្រែប្រួលទៅតាមយេនឌ័រ អាយុ ពិការភាព និងកត្តាសង្គមផ្សេងទៀត។
- ប្រើប្រាស់ SADDD ក្នុងសាវតាហានិភ័យ និងផែនទីមុខសញ្ញាគ្រោះថ្នាក់ រួចវិភាគផលប៉ះពាល់នៃកត្តាសង្គមលើកម្រិតនៃការប្រឈមនឹងហានិភ័យ។

សំណួរក្នុងគំរូ HVCA ដែលឆ្លើយតបនឹងតម្រូវការយេនឌ័រប្រកបដោយបរិយាប័ន្នសង្គមសម្រាប់ប្រភេទផ្សេងៗនៃសមត្ថភាព និងភាពងាយរងគ្រោះ

| ប្រភេទនៃសមត្ថភាព | គំរូសំណួរដែលឆ្លើយតបនឹងតម្រូវការយេនឌ័រប្រកបដោយបរិយាប័ន្នសង្គម |
|---|---|
| **កាយសម្បទា ឬសម្ភារ**<br>បរិស្ថានរូបវន្តរបស់បុគ្គល លទ្ធភាពទទួលបានមូលធន សម្ភារ និងទ្រព្យសម្បត្តិសំខាន់ៗ ជំនាញ និងរបរចិញ្ចឹមជីវិត និងយុទ្ធសាស្ត្រដោះស្រាយ។ | - តើក្រុមផ្សេងៗក្នុងសហគមន៍មានសមត្ថភាពអ្វីខ្លះ ( ជនមានពិការភាព)? តើសមត្ថភាពទាំងនោះខុសគ្នា ឬទេ?<br>- តើមានធនធានផលិតភាព ជំនាញ និងបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ច និងសង្គមអ្វីខ្លះ? តើក្រុមណាខ្លះដែលគ្រប់គ្រងធនធានទាំងនេះ?<br>- តើក្រុមក្នុងសង្គមមានលទ្ធភាពខុសគ្នាក្នុងការទទួលបានសេវា និងទ្រព្យសម្បត្តិ ឬទេ? |
| **សង្គម ឬស្ថាប័ន**<br>សមាសភាគសង្គមរបស់សហគមន៍មួយ ដូចជា ប្រព័ន្ធធ្វើសេចក្តីសម្រេចចិត្តផ្លូវការ និងក្រៅផ្លូវការ។ | - តើស្ត្រី និងបុរសប្រើប្រាស់រចនាសម្ព័ន្ធផ្លូវការ និងក្រៅផ្លូវការអ្វីខ្លះដើម្បីធ្វើសេចក្តីសម្រេចចិត្ត និងរៀបចំសកម្មភាពសង្គម និងសេដ្ឋកិច្ច មុនពេលមានគ្រោះមហន្តរាយ? តើគ្រោះមហន្តរាយនាពេលអនាគតអាចបង្កផលប៉ះពាល់ដូចម្តេចលើរចនាសម្ព័ន្ធ និងប្រព័ន្ធសង្គមទាំងនេះ?<br>- តើក្រុមជួបការលំបាកក្នុងសង្គម ដូចជាស្ត្រី ចូលរួមកម្រិតណាក្នុងរចនាសម្ព័ន្ធផ្លូវការ និងប្រព័ន្ធក្រៅផ្លូវការ ដែលមានការធ្វើសេចក្តីសម្រេចចិត្តស្តីពីសកម្មភាពសង្គម និងសេដ្ឋកិច្ច?<br>- តើមានឧបសគ្គផ្នែកសង្គម និងវប្បធម៌ដែលរារាំងការចូលរួមរបស់ពួកគេ ឬទេ? |
| **កម្លាំងចិត្ត និងឥរិយាបថ**<br>កត្តាវប្បធម៌ និងចិត្តសាស្ត្រ | - តើក្រុមផ្សេងៗក្នុងសង្គម ( ស្ត្រី និងបុរស) យល់យ៉ាងណាចំពោះខ្លួនឯង និងសមត្ថភាពរបស់ខ្លួនក្នុងការប្រឈមមុខដោយប្រសិទ្ធភាពជាមួយបរិស្ថានសង្គម និងការប្រែប្រួល?<br>- តើមានតួនាទី និងឱកាសអ្វីខ្លះ ( តួនាទី និងទំនាក់ទំនងយេនឌ័រ) សម្រាប់សមាជិកសហគមន៍? តើគ្រោះមហន្តរាយបង្កផលប៉ះពាល់ដូចម្តេចលើតួនាទី និងឱកាសទាំងនោះ? |

## ៤.១.១.២.ការរៀបចំផែនការត្រៀមបម្រុង និងការធ្វើលំហាត់សាកល្បងឆ្លើយតបគ្រោះអាសន្ន

បន្ទាប់ពីបានកំណត់ភាពងាយរងគ្រោះរបស់ក្រុមផ្សេងៗក្នុងសង្គមក្នុង HVCAs និងការធ្វើលំហាត់សាកល្បងឆ្លើយតបគ្រោះអាសន្ន ការរៀបចំផែនការត្រៀមបម្រុងឆ្លើយតបជាឱកាសសម្រាប់ការកសាងភាពធន់របស់សហគមន៍។ ធាតុផ្សំដ៏សំខាន់មួយនៃការរៀបចំផែនការនេះគឺការធានាថាក្រុមទាំងអស់ក្នុងសង្គមមានលទ្ធភាពពេញលេញ និងស្មើភាពក្នុងការទទួលបានការការពារផ្នែកហិរញ្ញវត្ថុ។ ក្រៅពីនេះ ស្ត្រីអាចមានការលំបាកក្នុងការបើកគណនីធនាគារផ្ទាល់ខ្លួន ការកសាង

ភាពធន់របស់ស្ត្រីទៅនឹងគ្រោះមហន្តរាយ រួមមានការបង្កើនលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានឥណទាន ទ្រព្យសម្បត្តិ និងធនធានហិរញ្ញវត្ថុ តាមរយៈ៖

- ការប្រើប្រាស់ការវាយតម្លៃនៅកម្រិតបុគ្គលដែលបែងចែកជាប្រភេទ ឬប៉ារ៉ាម៉ែត្រ ដូចជាគ្រួសារមានស្ត្រីជាមេគ្រួសារគ្រួសាររស់នៅក្នុងផ្ទះតែមួយ និងស្ត្រីមេម៉ាយ ក្នុងផែនការ និងកម្មវិធីការពារហិរញ្ញវត្ថុ។
- ការបង្កើតប្រព័ន្ធកិច្ចការពារសង្គមដែលមានភាពបត់បែន ដែលគ្របដណ្តប់លើក្រុមក្នុងសង្គមដែលកំពុងប្រឈមនឹងបញ្ហាលទ្ធភាពប្រើប្រាស់/លទ្ធភាពទទួលបាន (ដូចជា ស្ត្រីចំណាស់ និងស្ត្រីមានពិការភាព)។
- ការខិតខំបង្កើនលទ្ធភាពទទួលបានហិរញ្ញវត្ថុសម្រាប់ស្ត្រីដែលងាយរងគ្រោះដោយសារផលប៉ះពាល់នៃគ្រោះមហន្តរាយ តាមរយៈយន្តការនានា ដូចជា មីក្រូឥណទាន មីក្រូហិរញ្ញវត្ថុ និងរបបប្រាក់សន្សំ។
- ការគាំទ្រដល់ស្ត្រីដែលងាយរងគ្រោះដោយសារផលប៉ះពាល់នៃគ្រោះមហន្តរាយឱ្យបង្កើនប្រភពប្រាក់ចំណូល និងរបរចិញ្ចឹមជីវិតរបស់ពួកគេ។

**បញ្ជីត្រួតពិនិត្យការរៀបចំផែនការត្រៀមបម្រុងឆ្លើយតបនៅកម្រិតសហគមន៍ប្រកបដោយបរិយាប័ន្ន៖**

- ដាក់បញ្ចូលសកម្មភាពគ្រប់គ្រងគ្រោះមហន្តរាយ ក្នុងកម្មវិធីកិច្ចការពារសង្គមតាមសហគមន៍ជាពិសេសសម្រាប់ក្រុមពាក់ព័ន្ធ។
- បង្កើតគំនិតផ្តួចផ្តើមអប់រំ និងកសាងការយល់ដឹងក្នុងសហគមន៍ស្តីពីហានិភ័យគ្រោះមហន្តរាយ និងភាពធន់ដែលផ្តោតលើក្រុមពាក់ព័ន្ធក្នុងសង្គមដូចជាសហគមន៍ជនជាតិភាគតិចវិធីសាស្ត្របណ្តុះបណ្តាលគ្រូបង្គោល ឬយុទ្ធនាការបណ្តាញផ្សព្វផ្សាយ អាចជួយពង្រីកគំនិតផ្តួចផ្តើមនេះ។
- ប្រើប្រាស់ល្បែងកំសាន្តក្រៅផ្លូវការ ការប្រកួតប្រជែង ឯកសារបោះពុម្ពផ្សាយ និងការហ្វឹកហាត់ត្រៀមបង្ការ ដើម្បីជំរុញការចូលរួមរបស់សិស្សសាលាទាំងពីរភេទ ក្នុងយុទ្ធសាស្ត្រត្រៀមបង្ការគ្រោះមហន្តរាយ រួមទាំងបញ្ហាប្រឈមរបស់ក្មេងស្រីក្នុងការឆ្លើយតបគ្រោះមហន្តរាយ និងរបៀបកាត់បន្ថយបញ្ហាប្រឈមទាំងនោះ។
- ធានាថា ក្រុមទាំងអស់ក្នុងសង្គម រួមទាំងជនមានពិការភាព អាចប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗដូចជា ទីទួលសុវត្ថិភាព និងលំនៅដ្ឋានសង្គ្រោះបន្ទាន់ដោយផ្តល់ព័ត៌មានជាភាសាក្នុងមូលដ្ឋានស្តីពីហេដ្ឋារចនាសម្ព័ន្ធសង្គ្រោះបន្ទាន់ និងមានរូបភាពបង្ហាញលើក្តារប្រកាសព័ត៌មានក្នុងសហគមន៍។
- គាំទ្រវគ្គបណ្តុះបណ្តាលស្តីពីយុទ្ធសាស្ត្រដោះស្រាយក្នុងមជ្ឈដ្ឋានគ្រោះមហន្តរាយ ដូចជាការបង្រៀនហែលទឹកក្នុងតំបន់ងាយប្រឈមនឹងគ្រោះទឹកជំនន់ សម្រាប់ក្រុមក្នុងសង្គមដែលមិនទាន់បានរៀនសូត្រយុទ្ធសាស្ត្រទាំងនេះ។
- ជួយដល់ស្ត្រី ក្មេងស្រី និងក្រុមផ្សេងទៀតក្នុងសង្គមឱ្យទទួលបានអត្តសញ្ញាណប័ណ្ណ និងគណនីធនាគារដើម្បីទទួលបានការគាំទ្រក្នុងការឆ្លើយតបគ្រោះមហន្តរាយ។

- ប្រសិនបើអាច សហការជាមួយវិស័យផ្សេងៗដើម្បីបង្កើតយន្តការបញ្ជូនករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងនីតិវិធីប្រតិបត្តិស្តង់ដារដែលបញ្ជាក់ពីតួនាទី និងការទទួលខុសត្រូវលើការឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ផ្តល់ និងបង្កភាពងាយស្រួលដល់ប្រជាជនក្នុងការទទួលបានព័ត៌មានស្តីពីសេវាអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

ការរៀបចំផែនការយថាហេតុនៅកម្រិតសហគមន៍ ផ្តល់មូលដ្ឋានព័ត៌មានដល់ការរៀបចំផែនការនៅថ្នាក់តំបន់ និងថ្នាក់ជាតិ។ ដូច្នេះគេអាចអនុវត្តស្តង់ដារដូចគ្នាសម្រាប់បរិបទសង្គមក្នុងផែនការត្រៀមបង្ការ និងឆ្លើយតបគ្រោះអាសន្នតាមវិស័យ និងការរៀបចំផែនការយថាហេតុនៃវេទិកាឆ្លើយតបមនុស្សធម៌។

## ៤.១.២.ការកាត់បន្ថយគ្រោះថ្នាក់

### ៤.១.២.១.ការប្រកាសឱ្យដឹងមុន និងបណ្តាញប្រាស្រ័យទាក់ទង

ប្រព័ន្ធប្រកាសឱ្យដឹងមុន មានប្រសិទ្ធភាពបំផុតនៅពេលដែលប្រព័ន្ធទាំងនោះកត់សម្គាល់ និងដាក់បញ្ចូលភាពផ្សេងៗរបស់បុគ្គល និងក្រុមក្នុងសង្គម។ ចាំបាច់ត្រូវបង្កើតប្រព័ន្ធទាំងនេះដោយផ្អែកតាមការសន្មតថា ក្រុមក្នុងសង្គមមានកម្រិតចំណេះដឹងខុសគ្នា ស្តីពីហានិភ័យមានស្រាប់ក្នុងសហគមន៍ ដូចជា ក្នុងសហគមន៍មួយចំនួនផ្នត់គំនិត និងតួនាទីយេនឌ័រអាចផាត់ចេញលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានព័ត៌មាន ឬការចូលរួមក្នុងវគ្គបណ្តុះបណ្តាល។ HVCAs អាចផ្តល់ព័ត៌មានចាំបាច់ស្តីពីការយល់ឃើញ និងការវាយតម្លៃហានិភ័យដោយក្រុមផ្សេងៗក្នុងសង្គម។ ផ្អែកតាមតួនាទីក្នុងសង្គម និងសេដ្ឋកិច្ច ក្រុមក្នុងសង្គមអាចកំណត់ខុសៗគ្នាអំពីការចាប់ផ្តើមឡើងនៃគ្រោះមហន្តរាយ និងផ្តោតអាទិភាពលើទិដ្ឋភាពផ្សេងៗនៃការត្រៀមខ្លួនបង្ការគ្រោះមហន្តរាយ។

ក្រុមផ្សេងៗក្នុងសង្គម ដូចជា បុរស និងស្ត្រី ទទួលបានព័ត៌មានប្រកាសឱ្យដឹងមុនពីប្រភពផ្សេងៗ រួចបកស្រាយ និងឆ្លើយតបទៅនឹងព័ត៌មានទាំងនេះតាមរបៀបខុសៗគ្នា។ លំហូរព័ត៌មានក្នុងសហគមន៍ទទួលរងឥទ្ធិពលពីកត្តាជាច្រើន ដូចជា យេនឌ័រ ស្ថានភាពសង្គម សមត្ថភាព និងទីតាំង និងជាញឹកញាប់ មិនបានផ្សព្វផ្សាយដល់ស្ត្រីដែលរស់នៅតំបន់ដាច់ស្រយាល។ ប្រព័ន្ធប្រកាសឱ្យដឹងមុន ១២៩៤ របស់កម្ពុជាតម្រូវឱ្យអ្នកប្រើប្រាស់មានទូរស័ព្ទចល័តដែលបានចុះឈ្មោះប្រើប្រាស់ ដើម្បីទទួលបានការប្រកាសឱ្យដឹងពីមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ។ ជនមានពិការភាពអាចមានការលំបាកក្នុងការទទួលបានព័ត៌មានប្រកាសឱ្យដឹងមុន ដូចជាការប្រកាសពីការជម្លៀសច្រើនតែមានទម្រង់ជាសំឡេង ( តាមរយៈសីរ៉ែន និងឧបករណ៍បំពងសំឡេង) ដែលមិនបំពេញតម្រូវការរបស់ជនពិការគថ្លង់ ឬជនមានកម្សោយក្នុងការស្តាប់។ ដំណោះស្រាយមានដូចជាការផ្ញើរអ៊ីមែលប្រកាសឱ្យដឹងមុនទៅជនមានពិការភាព ការប្រើប្រាស់បច្ចេកវិទ្យា ដូចជាការដាក់ពាក្យ/ឃ្លារៀបរាប់សម្រាប់ការផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ និងការចុះជួបតាមខ្នងផ្ទះដោយអ្នកស្ម័គ្រចិត្តសម្រាប់អ្នកដែលមិនបានទទួលព័ត៌មានប្រកាសឱ្យដឹងមុន។ ការផ្សព្វផ្សាយព័ត៌មានប្រកាសឱ្យដឹងមុនតាមរយៈមធ្យោបាយផ្សេងៗក្រៅពីវិធីសាស្ត្រដែលផ្តោតលើក្រុមក្នុងសង្គម ដូចជាជនមានពិការភាពអាចធានាបានថាសមាជិកសហគមន៍ទាំងអស់នឹងទទួលបានព័ត៌មានដូចគ្នា។

**បញ្ជីត្រួតពិនិត្យប្រព័ន្ធប្រកាសឱ្យដឹងមុន និងការផ្សព្វផ្សាយពីហានិភ័យដែលប្រកដដោយបរិយាប័ន្នៈ**

- អាចឱ្យប្រព័ន្ធប្រកាសឱ្យដឹងមុនផ្តោតលើស្រ្តី និងបុរសនៃក្រុមផ្សេងៗក្នុងសង្គម និងបរិបទមុខសញ្ញាគ្រោះថ្នាក់ និងផ្តល់លទ្ធភាពស្មើភាពដល់ក្រុមទាំងអស់ក្នុងការប្រើប្រាស់ប្រព័ន្ធប្រកាសឱ្យដឹងមុន។
- បង្កើត និងផ្សព្វផ្សាយការប្រកាសឱ្យដឹង ដែលអាចឱ្យក្រុមផ្សេងៗក្នុងសង្គមយល់បាន (ស្រ្តី និងក្មេងស្រី និងជនមានពិការភាព)។
- លើកកម្ពស់ការចូលរួមរបស់ក្រុមជួបការលំបាកក្នុងការហ្វឹកហាត់ត្រៀមបង្ការគ្រោះមហន្តរាយ និងការបង្កើតប្រព័ន្ធប្រកាសឱ្យដឹងមុន និងការផ្សព្វផ្សាយពីហានិភ័យ។
- បណ្តុះបណ្តាលស្រ្តី និងក្រុមផ្សេងៗក្នុងសង្គមដែលងាយរងគ្រោះដោយសារផលប៉ះពាល់នៃគ្រោះមហន្តរាយអំពីរបៀបដំឡើង ដំណើរការ និងថែទាំប្រព័ន្ធប្រកាសឱ្យដឹងមុន។
- ដាក់បញ្ចូលភាពងាយរងគ្រោះ និងសមត្ថភាពរបស់ក្រុមផ្សេងៗក្នុងសង្គម ដូចជា ស្រ្តី និងជនមានពិការភាព ក្នុងផែនការប្រព័ន្ធប្រកាសឱ្យដឹងមុន និងការផ្សព្វផ្សាយពីហានិភ័យ។

### ៤.១.២.២.ការបង្កើត និងគ្រប់គ្រងទីទួលសុវត្ថិភាព

ស្រ្តី និងក្រុមជួបការលំបាកផ្សេងទៀតក្នុងសង្គម មានអាទិភាព និងតម្រូវការចម្រុះក្នុងស្ថានភាពគ្រោះមហន្តរាយ ដែលចាំបាច់ត្រូវដាក់បញ្ចូលក្នុងការរៀបចំផែនការ និងថវិកាសម្រាប់ទីទួលសុវត្ថិភាព។ ក្រុមពាក់ព័ន្ធក្នុងសង្គមគួរតែអាចចូលរួមពេញលេញ និងដោយស្មើភាពក្នុងការបង្កើតទីទួលសុវត្ថិភាព ដូចជាក្នុងការធ្វើសេចក្តីសម្រេចចិត្តស្តីពីសន្តិសុខ។ សេវាសន្តិសុខគួរត្រួតពិនិត្យគ្រប់ពេលលើផ្នែកដែលមានហានិភ័យខ្ពស់ក្នុងទីទួលសុវត្ថិភាព មន្ត្រីនៅទីទួលសុវត្ថិភាពត្រូវយល់ច្បាស់ពីបរិយាប័ន្នសង្គម និងសមភាពយេនឌ័រ និងទទួលបានការបណ្តុះបណ្តាលគ្រប់គ្រាន់ស្តីពីការបញ្ជូនជនរងគ្រោះទៅរកការគាំទ្រផ្នែកចិត្តសង្គម សេវាឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ។

ទីទួលសុវត្ថិភាព ត្រូវផ្តល់សេវាចម្រុះដល់អ្នកស្នាក់នៅក្នុងទីតាំង ដែលសេវាជាច្រើនអាចត្រូវបានផ្តល់ជូនដោយអង្គភាពកណ្តាលក្នុងទីតាំង ដូចជាផ្តល់ការពិគ្រោះយោបល់ផ្នែកចិត្តសង្គម ការគាំទ្រសម្រាប់ការប៉ះទង្គិចផ្លូវចិត្ត ជំនួយផ្លូវច្បាប់ និងការកសាងការយល់ដឹងស្តីពីការគាំទ្រផ្នែកសេដ្ឋកិច្ច ដូចជា ឱកាសធ្វើការងារបានប្រាក់។

**បញ្ជីត្រួតពិនិត្យទីទួលសុវត្ថិភាពដែលមានលក្ខណៈបរិយាប័ន្នៈ**

- ហេដ្ឋារចនាសម្ព័ន្ធគួរឆ្លើយតប តម្រូវការ និងការចង់បានផ្នែកសង្គម វប្បធម៌ និងសេដ្ឋកិច្ចរបស់បុរស និងស្រ្តី និងក្រុមផ្សេងៗក្នុងសង្គម ត្រូវផ្តោតការយកចិត្តលើកង្វល់សុវត្ថិភាពរបស់ពួកគេ ដូចជាទីតាំងប្រភពទឹក អគ្គីសនី និងមូលដ្ឋានអនាម័យជាដើម។
- ទីទួលសុវត្ថិភាព ត្រូវមានមូលដ្ឋានអនាម័យដាច់ដោយឡែកសម្រាប់បុរស-ក្មេងប្រុស និងស្រ្តី-ក្មេងស្រី និងគួរសម្គាល់ដោយស្លាកសញ្ញាច្បាស់លាស់។ មូលដ្ឋានអនាម័យត្រូវមានភាពសមស្របក្នុងវប្បធម៌ ស្ថិតក្នុងទីតាំងសុវត្ថិភាព និងផ្តល់ភាពឯកជន ( មានគន្លឹះចាក់ពីខាងក្នុង)។

- ទីទួលសុវត្ថិភាព ត្រូវមានហេដ្ឋារចនាសម្ព័ន្ធដែលសមស្របក្នុងវប្បធម៌ និងផ្តល់ភាពឯកជនសម្រាប់ស្ត្រី និងក្មេងស្រី ជាពិសេសស្ត្រីបំបៅដោះកូន។
- ហេដ្ឋារចនាសម្ព័ន្ធគួរផ្តល់សុវត្ថិភាពដល់ក្រុមទាំងអស់ក្នុងសង្គម ជាពិសេសក្រុមដែលប្រឈមនឹងហានិភ័យខ្ពស់នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ ( ការផ្តល់ភ្លើងបំភ្លឺគ្រប់គ្រាន់នៅពេលយប់)។
- ហេដ្ឋារចនាសម្ព័ន្ធត្រូវតែអាចឱ្យមនុស្សគ្រប់រូបចេញចូលបាន ដូចជា ចាស់ជរា និងជនមានពិការភាពផ្នែកចល័តភាព។
- ទីទួលសុវត្ថិភាពត្រូវមានបុគ្គលិកសន្តិសុខ និងមន្ត្រីគ្រប់គ្រងច្បាស់លាស់។
- ឱកាសស្មើភាពក្នុងការទទួលបានការបណ្តុះបណ្តាលស្តីពីការដំណើរការ និងការថែទាំប្រព័ន្ធទឹកស្អាត និងអនាម័យ ដើម្បីលើកទឹកចិត្តឱ្យមានការចែករំលែកការទទួលខុសត្រូវក្នុងគ្រួសារ។

### ៤.១.៣.ការត្រៀមរៀបចំ

ការត្រៀមរៀបចំសម្រាប់ការឆ្លើយតបសង្គ្រោះបន្ទាន់រួមមានមធ្យោបាយដឹកជញ្ជូន សម្ភារឧបករណ៍សង្គ្រោះ ស្បៀងបម្រុង ទីទទួលសុវត្ថិភាព សម្ភារប្រើប្រាស់ និងតម្រូវការចាំបាច់របស់ស្ត្រីជាដើម។

#### ៤.១.៣.១.ការប្រជុំត្រៀមបម្រុងមុនរដូវកើតមានគ្រោះមហន្តរាយ

កិច្ចប្រជុំត្រៀមបម្រុងមុនរដូវកើតមានគ្រោះមហន្តរាយ ជាឱកាសក្នុងការវាយតម្លៃបរិយាប័ន្ននៃវិធានការគ្រប់គ្រងគ្រោះមហន្តរាយបច្ចុប្បន្ននិងធ្វើការកែប្រែចាំបាច់ចំណុចនេះ អាចរួមមានការវាយតម្លៃការចូលរួមរបស់ក្រុមដែលងាយរងគ្រោះដោយសារផលប៉ះពាល់នៃគ្រោះមហន្តរាយក្នុងក្រុមប្រតិបត្តិការ និងដឹកនាំការគ្រប់គ្រងគ្រោះមហន្តរាយ និងការចាត់វិធានការជាជំហានៗដើម្បីបង្កើនការចូលរួម (ប្រសិនបើពួកគេមានតំណាងតិចតួច)។

**តារាង ការបញ្ជ្រាបយេនឌ័រប្រកបដោយបរិយាប័ន្នសង្គម ក្នុងការរៀបចំផែនការគ្រប់គ្រងគ្រោះមហន្តរាយ**

| ផ្នែកនៃផែនការគ្រប់គ្រងគ្រោះមហន្តរាយ | ចំណុចចាប់ផ្តើមសម្រាប់ការដាក់បញ្ចូលយេនឌ័រប្រកបដោយបរិយាប័ន្នសង្គម |
|---|---|
| **ការវិភាគស្ថានភាព**<br>សេចក្តីសង្ខេបបរិបទគោលនយោបាយ និងមុខសញ្ញាគ្រោះថ្នាក់ដែលបានលើកឡើងក្នុងផែនការ។ ឱកាសបង្កើតមូលដ្ឋានសម្រាប់អភិក្រមបែបបរិយាប័ន្ន។ | ▪ ផ្តល់សំអាងលើភាពពាក់ព័ន្ធនៃការលើកឡើងពីសមភាពយេនឌ័រ និងបរិយាប័ន្នសង្គម រួមទាំងការយោងតាមឯកសារគោលនយោបាយ និងក្របខណ្ឌពាក់ព័ន្ធ<br>▪ លើកឡើងពីទិដ្ឋភាពយេនឌ័រ និងសង្គមនៃហានិភ័យដែលបានកំណត់ក្នុងផែនការ។ |

| | |
|---|---|
| **ទស្សនវិស័យ គោលបំណង និងគោលការណ៍ណែនាំ**<br>ការប្តេជ្ញាចិត្តជាក់លាក់ក្នុងផ្នែកនេះជួយជំរុញគោលការណ៍ណែនាំការបញ្ជ្រាបយេនឌ័រ និងបរិយាប័ន្នសង្គមក្នុងផែនការនេះ។ | ▪ រួមបញ្ចូលការប្តេជ្ញាចិត្តបង្កើនសមភាពយេនឌ័រ និងបរិយាប័ន្នសង្គម។<br>▪ កំណត់រកវិសមភាពសង្គមជាក់លាក់ដែលត្រូវលើកឡើងដោយផែនការនេះ ទន្ទឹមនឹងការកត់សម្គាល់ថាមនុស្សម្នាក់ អាចទទួលរងទម្រង់ចម្រុះនៃការផាត់ចេញ។ |
| **ចំណុចយុទ្ធសាស្ត្រក្នុងសកម្មភាព**<br>ជាញឹកញាប់ផែនការកំណត់ចំណុចសកម្មភាពធៀបនឹងក្របខណ្ឌសេនដាយ គួរកំណត់រកតួនាទី និងសមត្ថភាពរបស់ក្រុមពាក់ព័ន្ធផ្សេងៗក្នុងសង្គម និងផ្អែកលើទស្សនចម្រុះរបស់ពួកគេ។ | ▪ បញ្ចូលទិដ្ឋភាពសង្គមនៃហានិភ័យគ្រោះមហន្តរាយ (ផ្អែកតាម HVCAs ប្រកបដោយបរិយាប័ន្ន)។<br>▪ លើកកម្ពស់សមភាពសង្គមក្នុងដំណើរការពង្រឹងស្ថាប័នគ្រប់គ្រងគ្រោះមហន្តរាយ ( ការជួលបុគ្គលិកបន្ថែមទៀតពីក្នុងចំណោមក្រុមមានតំណាងតិចតួច)។<br>▪ ពិចារណាពីតួនាទីរបស់ក្រុមចម្រុះក្នុងសង្គមក្នុងការរៀបចំផែនការត្រៀមបម្រុង និងប្រព័ន្ធប្រកាសឱ្យដឹងមុន។ |
| **ការអនុវត្ត និងប្រតិបត្តិការ**<br>គួរផ្តោតការយកចិត្តទុកដាក់លើរបៀបកាត់បន្ថយបញ្ហាយេនឌ័រ និងបរិយាប័ន្នសង្គម។ | ▪ លើកកម្ពស់ការចូលរួមរបស់ស្ត្រី និងក្រុមមានតំណាងតិចតួចផ្សេងទៀតក្នុងការធ្វើសេចក្តីសម្រេចចិត្ត។<br>▪ បែងចែកធនធានសម្រាប់ការអនុវត្តសកម្មភាពដែលឆ្លើយតបនឹងតម្រូវការយេនឌ័រប្រកបដោយបរិយាប័ន្នសង្គម។<br>▪ ធ្វើការពិនិត្យតាមដាន និងវាយតម្លៃដែលឆ្លើយតបនឹងតម្រូវការយេនឌ័រប្រកបដោយបរិយាប័ន្នសង្គម ដូចជាសូចនាករយេនឌ័រ និងបរិយាប័ន្នសង្គម និងការប្រមូល SADDD។ |

#### ៤.១.៣.២.ការបណ្តុះបណ្តាល និងអន្តរាគមន៍អភិវឌ្ឍន៍សមត្ថភាពផ្សេងៗ

ដើម្បីធានាអភិក្រមប្រកបដោយបរិយាប័ន្ន នៅគ្រប់ដំណាក់កាលនៃវដ្តគ្រប់គ្រងគ្រោះមហន្តរាយ អ្នកតាក់តែងគោលនយោបាយ និងមន្ត្រីកម្មវិធីដែលធ្វើការងារពាក់ព័ន្ធនឹងការគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវយល់ច្បាស់ពីយេនឌ័រប្រកបដោយបរិយាប័ន្នសង្គម (តាមរយៈសកម្មភាពបង្កើនការយល់ដឹង និងកសាងសមត្ថភាព)។ ខាងក្រោមនេះជាសមត្ថភាពសំខាន់ៗដែលត្រូវអភិវឌ្ឍតាមរយៈការបណ្តុះបណ្តាល៖

- ការយល់ពីយេនឌ័រ និងតួនាទីយេនឌ័រ។
- ការកត់សម្គាល់របៀបដែលភាពងាយរងគ្រោះបង្កឡើងដោយវិសមភាពនៃទំនាក់ទំនងក្នុងសង្គម និងសេដ្ឋកិច្ច។
- ការបកស្រាយ SADDD និងសូចនាករយេនឌ័រ និងបរិយាប័ន្នសង្គម។
- ការប្រើប្រាស់ការវិភាគយេនឌ័រកម្រិតមូលដ្ឋាន។
- ការបញ្ជ្រាបយេនឌ័រ និងបរិយាប័ន្នក្នុងផែនការ គោលនយោបាយ និងប្រតិបត្តិការគ្រប់គ្រងគ្រោះមហន្តរាយ។

មន្ត្រីដែលធ្វើការងារផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវមានសមត្ថភាពច្រើនជាងបុគ្គលផ្សេងទៀត និងអាចទទួលបានការអភិវឌ្ឍសមត្ថភាព និងជំនាញ។

ការអភិវឌ្ឍសមត្ថភាពត្រូវរួមបញ្ចូលគន្លឹះស្តីពីអន្តរាគមន៍ផ្លាស់ប្តូរសង្គម ដូចជាការចូលរួមជាមួយបុរស និងក្មេងប្រុស ដើម្បីផ្លាស់ប្តូរបទដ្ឋានយេនឌ័របែបរើសអើង។ បទដ្ឋានយេនឌ័រតឹងរ៉ឹងមិនត្រឹមតែធ្វើឱ្យស្ត្រី និងក្មេងស្រីជួបការលំបាកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរារាំងបុរស និងក្មេងប្រុសមិនឱ្យសម្រេចបានសក្តានុពលរបស់ខ្លួនទៀតផង ព្រោះសម្ពាធដែលបង្ខំឱ្យពួកគេអនុវត្តតាមភាពជាបុរសអវិជ្ជមាន ច្រើនតែធ្វើឱ្យបុរសវ័យក្មេងប្រឡូកក្នុងឥរិយាបថប្រថុយប្រថាន និងគ្រោះថ្នាក់។ កម្មវិធីដែលលើកកម្ពស់សមភាពយេនឌ័រ អាចកែសម្រួលការកំណត់ភាពជាបុរសឱ្យមានលក្ខណៈជ្រោមជ្រែង សហការ និងអហិង្សាតាមរយៈការគាំទ្រឱ្យបុរសប្រព្រឹត្តដោយការទទួលខុសត្រូវ និងការគាំទ្រក្នុងតួនាទីគ្រួសាររបស់ពួកគេ។ ក្រៅពីនេះកម្មវិធីអាចជំរុញការចូលរួមរបស់បុរសឆ្នើមដែលគោរពសិទ្ធិស្ត្រី និងគាំទ្រការបែងចែកកិច្ចការគ្រួសារដែលមិនទទួលបានប្រាក់ឈ្នួលដោយស្មើភាពរវាងបុរស និងស្ត្រី។

ជាញឹកញាប់អន្តរាគមន៍ផ្លាស់ប្តូរដែលបង្កើនអំណាចក្នុងសង្គម ឬលទ្ធភាពទទួលបានធនធានរបស់ក្រុមក្នុងសង្គមអាចបង្កើតឱ្យមានការឆ្លើយតបអវិជ្ជមានពីក្រុមដែលយល់ថា ពួកគេទទួលរងការគំរាមកំហែង។ ការសំខាន់គឺត្រូវពិនិត្យរកផលវិបាកអវិជ្ជមានដែលលេចឡើងដោយអចេតនា និងដើម្បីធ្វើការកាត់បន្ថយ។ ជំហានក្នុងការកាត់បន្ថយផលប៉ះពាល់រួមមាន ការធានា ការចូលរួមពេញលេញរបស់ក្រុមជួបការលំបាកក្នុងគម្រោងនេះ ការរួមបញ្ចូលអ្នកដឹកនាំសហគមន៍ និងអ្នកដឹកនាំសាសនាក្នុងដំណើរការនេះ និងការគាំទ្រឱ្យសហគមន៍វាយតម្លៃខ្ពស់លើអត្ថប្រយោជន៍នៃយេនឌ័រ និងទម្រង់ផ្សេងទៀតនៃសមភាពសង្គម។

## ៤.២.យេនឌ័រក្នុងការឆ្លើយតបសង្គ្រោះបន្ទាន់

ក្នុងពេលឆ្លើយតបសង្គ្រោះបន្ទាន់ ការសំខាន់គឺត្រូវកំណត់រក និងបំពេញតម្រូវការរបស់ក្រុមក្នុងសង្គមដែលងាយរងគ្រោះបំផុតដោយសារផលប៉ះពាល់នៃគ្រោះមហន្តរាយ ដើម្បីធានាថា ពួកគេមិនទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ។ ស្ត្រី និងក្មេងស្រីងាយរងគ្រោះដោយសារផលប៉ះពាល់នៃគ្រោះមហន្តរាយ និងងាយទទួលរងអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងដំណាក់កាលឆ្លើយតបគ្រោះមហន្តរាយ។ តាមស្ថិតិបង្ហាញថាឧប្បត្តិហេតុអំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមទាំងការកេងប្រវ័ញ្ច និងការរំលោភបំពានច្រើនតែកើនឡើងខ្លាំងក្រោយពេលគ្រោះមហន្តរាយ ដូច្នេះការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការគាំទ្រដល់ជនរងគ្រោះគួរតែជាចំណុចអាទិភាពនៅដំណាក់កាលនេះ។

### ៤.២.១.ការសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធក្នុងគ្រោះអាសន្ន

ការសម្របសម្រួលអ្នកពាក់ព័ន្ធក្នុងការឆ្លើយតបគ្រោះអាសន្ននឹងជួយកំណត់រក និងឆ្លើយតបតម្រូវការផ្សេងៗរបស់ក្រុមក្នុងសង្គមដែលងាយរងគ្រោះបំផុត ដោយសារផលប៉ះពាល់អវិជ្ជមាននៃគ្រោះមហន្តរាយ។ ចំណុចនេះទាមទារការសម្របសម្រួលយ៉ាងមានប្រសិទ្ធភាពរវាងតួអង្គគ្រប់គ្រងគ្រោះមហន្តរាយ ដូចជាអង្គការសហប្រជាជាតិ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការមនុស្សធម៌ជាតិ និងអន្តរជាតិ (វេទិកាឆ្លើយតបមនុស្សធម៌ វេទិកាមនុស្សធម៌កម្ពុជា និងដៃគូត្រៀមបង្ការកម្ពុជា ជានាទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពរវាងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និង

តួអង្គផ្សេងទៀតក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ)។ គណៈកម្មាធិការ សហគមន៍គ្រប់គ្រងគ្រោះមហន្តរាយអាចចូលរួមក្នុងការពិគ្រោះយោបល់ និងការផ្តល់យោបល់ត្រឡប់ ដោយដើរតួនាទីជាបណ្តាញទំនាក់ទំនងរវាងអ្នកធ្វើសេចក្តីសម្រេចចិត្តស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងសហគមន៍រងផលប៉ះពាល់។

ដើម្បីឱ្យការឆ្លើយតបគ្រោះអាសន្នកាន់តែឆ្លើយតបនឹងតម្រូវការយេនឌ័រប្រកបដោយបរិយាប័ន្នសង្គម ក្នុងការពិគ្រោះយោបល់ និងការសម្របសម្រួលអ្នកពាក់ព័ន្ធគួរខិតខំប្រឹងប្រែងលើកកម្ពស់ការចូលរួមប្រកបដោយអត្ថន័យរបស់ជនមានពិការភាព ដែលមានតំណាងតិចតួចក្នុងអភិបាលកិច្ចនិងការធ្វើសេចក្តីសម្រេចចិត្ត និងទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារគ្រោះមហន្តរាយ ដើម្បីធានាថា មនុស្សគ្រប់រូបអាចចូលរួមប្រកបដោយអត្ថន័យ ឬការបកប្រែភាសាសញ្ញាសម្រាប់ជនពិការគថ្លង់ ឬមានកម្សោយក្នុងការស្តាប់។

### ៤.២.២.ការប៉ាន់ប្រមាណតម្រូវការក្នុងគ្រោះអាសន្ន ការប្រមូលទិន្នន័យ ការវិភាគ និងការធ្វើរបាយការណ៍ពីគ្រោះមហន្តរាយ

**អំពើហិង្សាទាក់ទងនឹងយេនឌ័រ**

- យោងតាមអនុសាសន៍ទូទៅលេខ ៣៧ អំពើហិង្សាទាក់ទងនឹងយេនឌ័ររួមបញ្ចូលអំពើហិង្សាក្នុងគ្រួសារអំពើហិង្សាផ្លូវភេទ អំពើហិង្សាផ្នែកសេដ្ឋកិច្ច ការជួញដូរមនុស្ស និងអាពាហ៍ពិពាហ៍ដោយបង្ខំ។ UNFPA បានកំណត់ស្តង់ដារអប្បបរមាចំនួន ១៨ សម្រាប់ការកាត់បន្ថយ ទប់ស្កាត់ និងឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងគ្រោះអាសន្នដូចខាងក្រោម ៖
- "ជនរងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដូចជា ស្ត្រី ក្មេងស្រី ក្មេងប្រុស និងបុរសអាចទទួលបានសេវាថែទាំសុខភាពដែលមានគុណភាព និងសង្គ្រោះអាយុជីវិត ដោយផ្តោតសំខាន់លើការគ្រប់គ្រងគ្លីនិកនៃអំពើរំលោភសេពសន្ថវៈ។
- "ជនរងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រទទួលបានការគាំទ្រសុខភាពផ្លូវចិត្ត និងចិត្តសង្គមដែលមានគុណភាពដោយផ្តោតសំខាន់លើការព្យាបាល ការបង្កើនភាពអង់អាច និងការជាសះស្បើយ។
- "រៀបចំវិធានការសុវត្ថិភាព និងសន្តិសុខដើម្បីទប់ស្កាត់ និងកាត់បន្ថយអំពើហិង្សាទាក់ទងនឹងយេនឌ័រនិងការពារជនរងគ្រោះ។
- "មានប្រព័ន្ធបញ្ជូនដើម្បីផ្សារភ្ជាប់ស្ត្រី ក្មេងស្រី និងក្រុមប្រឈមនឹងហានិភ័យផ្សេងទៀត ទៅនឹងសេវាទប់ស្កាត់ និងឆ្លើយតបពហុវិស័យទៅនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ឱ្យបានទាន់ពេលវេលា និងមានសុវត្ថិភាព។
- "ការគាំទ្រជនរងគ្រោះ និងការកាត់បន្ថយហានិភ័យអំពើហិង្សាទាក់ទងនឹងយេនឌ័រត្រូវបានដាក់បញ្ចូលក្នុងវិស័យមនុស្សធម៌នៅដំណាក់កាលនីមួយៗនៃវដ្តកម្មវិធី និងក្នុងការឆ្លើយតបគ្រោះអាសន្ន។

ការប៉ាន់ប្រមាណតម្រូវការក្នុងគ្រោះអាសន្នពាក់ព័ន្ធនឹងការកំណត់របស់ពីតម្រូវការរបស់ក្រុមផ្សេងៗក្នុងសង្គមក្រោយពេលគ្រោះមហន្តរាយ ដើម្បីផ្តល់ជំនួយសង្គ្រោះឱ្យបានគ្រប់គ្រាន់។ ការ

ប្រមូលទិន្នន័យបែងចែកតាមភេទឱ្យបានត្រឹមត្រូវក្នុងដំណាក់កាលទប់ស្កាត់ និងត្រៀមបង្ការគ្រោះមហន្តរាយ ជួយឱ្យក្រុមឆ្លើយតបគ្រោះមហន្តរាយកំណត់អត្តសញ្ញាណក្រុមងាយរងគ្រោះដោយសារផលប៉ះពាល់នៃគ្រោះមហន្តរាយ និងទទួលបានព័ត៌មានដើមគ្រាស្ដីពីសហគមន៍រងគ្រោះ។ ចំណុចទាំងនេះបង្កើនប្រសិទ្ធភាពនៃការវាយតម្លៃតម្រូវការក្នុងគ្រោះអាសន្ន។ការវំលេចផលប៉ះពាល់នៃគ្រោះមហន្តរាយលើក្រុមពាក់ព័ន្ធក្នុងសង្គម ធ្វើឱ្យការវិភាគ និងការឆ្លើយតបគ្រោះមហន្តរាយឆ្លើយតបនឹងតម្រូវការយេនឌ័រ និងមានបរិយាប័ន្នសង្គម។

ក្រុមប៉ាន់ប្រមាណតម្រូវការក្នុងគ្រោះអាសន្ន គួរមានតុល្យភាពយេនឌ័រ តំណាងឱ្យប្រជាជនដែលពួកគេកំពុងផ្ដល់សេវាជូន និងទទួលការបណ្ដុះបណ្ដាលស្ដីពីយេនឌ័រ និងបរិយាប័ន្នសង្គមដើម្បីកំណត់រកហានិភ័យ និងកត្តាបង្កភាពងាយរងគ្រោះលើសមាជិកសហគមន៍ទាំងអស់។ ស្ត្រី និងក្មេងស្រីដែលរងផលប៉ះពាល់ គួរត្រូវបានសម្ភាសន៍ដោយអ្នកប្រមូលទិន្នន័យជាស្ត្រី ដោយអ្នកប្រ មូលទិន្នន័យគួរផ្ដោតសំខាន់លើចំណុចខាងក្រោម ៖

- ការប្រមូល SADDD ស្ដីពីប្រជាជនរងផលប៉ះពាល់ និងប្រជាជនគោលដៅ។
- ការដាក់បញ្ចូលគ្រួសារមានស្ត្រីជាមេគ្រួសារ ជាក្រុមសំខាន់សម្រាប់ការប្រមូលព័ត៌មាន និងផ្ដល់សេវា។
- ការធ្វើសវនកម្មសុវត្ថិភាព និងភាពងាយរងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការដាក់បញ្ចូលសំណួរពាក់ព័ន្ធនឹងហានិភ័យអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងវិស័យផ្សេងទៀត (ដូចជា ភ្លើងបំភ្លឺទីទួលសុវត្ថិភាព ឬថាតើបុរស និងស្ត្រីមានបង្គន់ដាច់ពីគ្នាឬទេ)។
- ការសង្កេតមើលហានិភ័យពាក់ព័ន្ធនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដោយផ្អែកលើការបណ្ដុះបណ្ដាលស្ដីពីចំណុចដែលត្រូវយកចិត្តទុកដាក់ (មិនគួរសួរសំណួរផ្ទាល់ស្ដីពីបទពិសោធន៍ទទួលរងអំពើហិង្សាទាក់ទងនឹងយេនឌ័រឡើយ)។

### ៤.២.៣.ការផ្តល់ជំនួយសង្គ្រោះ

ចាំបាច់ត្រូវពិចារណាពីតម្រូវការរបស់ក្រុមផ្សេងៗក្នុងសង្គមពាក់ព័ន្ធនឹងជំនួយសង្គ្រោះ ដូចជាតម្រូវការតាមភេទ ដូចជាផលិតផលរក្សាអនាម័យនៅពេលមករដូវ និងតម្រូវការតាមវប្បធម៌ សម្លៀកបំពាក់សាសនា។ សម្ភារជំនួយគួររួមបញ្ចូលឃីតសម្រាប់សង្គ្រោះក្រោយរងការរំលោភបំពាន ដែលអាចជាចំណុចចាប់ផ្តើមសម្រាប់ការពាក់ព័ន្ធ ជាមួយជនរងគ្រោះដោយសារអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការផ្តល់ព័ត៌មានស្តីពីសេវាដែលមាន និងរបៀបទទួលបានសេវាទាំងនោះ។ ឃីតសម្រាប់សង្គ្រោះក្រោយរងការរំលោភបំពានអាចមានសម្ភារដែលជួយកាត់បន្ថយហានិភ័យអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដូចជា វិទ្យុទាក់ទង កញ្ចែ និងពិល។ ការស្រាវជ្រាវស្តីពីឃីតសម្រាប់សង្គ្រោះក្រោយរងការរំលោភបំពានរកឃើញថាសម្ភារទាំងនេះមានប្រយោជន៍ខ្លាំងណាស់។ ស្ត្រីលើកឡើងថា ការទទួលបានឃីតក្នុងពេលខ្វះខាតផ្តល់អត្ថប្រយោជន៍ និងធ្វើឱ្យពួកគេយល់ថា ពួកគេមិនត្រូវបានបំភ្លេចចោល។ ក្រៅពីនេះ ឃីតគួរមានសម្ភាររៀបចំផែនការគ្រួសារ ដូចជា ស្រោមអនាម័យ ដែលការពារការមានផ្ទៃពោះចៃដន្យ និងជំងឺកាមរោគ និងមានភាពសមស្របសម្រាប់ក្រុមផ្សេងៗ ដូចជាក្រុម LGBTI។ យោងតាមកញ្ចប់សេវាបឋមអប្បបរមារបស់ UNFPA សហគមន៍គួរមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលបានការគាំទ្រសម្រាប់ការរៀបចំផែនការគ្រួសារ និងសុខភាពផ្លូវភេទ និងការគាំទ្រផ្នែកចិត្តសង្គម ជាពិសេសអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ បុគ្គលិកគ្រប់គ្រងគ្រោះមហន្តរាយត្រូវច្បាមយកយោបល់ត្រឡប់ពីក្រុមផ្សេងៗក្នុងសង្គម ដើម្បីធានាថា កញ្ចប់សម្ភារជំនួយបំពេញតម្រូវការរបស់ក្រុមទាំងនោះ និងមានភាពពាក់ព័ន្ធ និងសមស្របក្នុងវប្បធម៌ ដើម្បីជួយដល់ការត្រៀមបម្រុងគ្រោះមហន្តរាយនាពេលអនាគត។

> **គន្លឹះសំខាន់ ៖ ការបង្កើនលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានជំនួយក្នុងគ្រោះមហន្តរាយ**
> ក្នុងប្រទេសជាច្រើន ស្ត្រីមិនអាចទទួលបានជំនួយក្នុងគ្រោះមហន្តរាយបានឡើយ ព្រោះពួកគេគ្មានឯកសារអត្តសញ្ញាណ ហើយឯកសារដីធ្លី និងទ្រព្យសម្បត្តិ អាចស្ថិតក្រោមឈ្មោះរបស់សមាជិកគ្រួសារជាបុរស។ ចំណុចនេះអាចបង្កបញ្ហាកាន់តែខ្លាំងសម្រាប់ស្ត្រីជាច្រើន ក្នុងការបើកគណនីធនាគារ និងសេវាផ្ទេរហិរញ្ញវត្ថុ។ ដូច្នេះ ចាំបាច់ត្រូវកែទម្រង់ប្រព័ន្ធចុះឈ្មោះសម្រាប់ការទទួលបានជំនួយក្នុងគ្រោះអាសន្ន ដើម្បីផ្តល់ឱកាស និងការគាំទ្រដល់ស្ត្រី និងក្រុមផ្សេងទៀតក្នុងសង្គម ក្នុងការទទួលបានឯកសារចាំបាច់។ ក្រៅពីនេះ គេអាចកែទម្រង់សេវាផ្សព្វផ្សាយដល់អតិថិជន ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នក ដែលមានបញ្ហាចល័តភាព និងមិនសូវមានពេលវេលា និងអ្នករស់នៅតំបន់ដាច់ស្រយាល។
> ធនាគារពិភពលោក ២០១១. សេចក្តីណែនាំលេខ ៧៖ ការធ្វើឱ្យបរចិញ្ចឹមជីវិត និងកិច្ចការពារសង្គមមានរំញោចយេនឌ័រ ។

ស្ត្រីមានតម្រូវការសុខភាពជាក់លាក់ ដូចជា សេវាថែទាំសុខភាពមាតា និងសេវាសម្រាលកូន។ ក្នុងវប្បធម៌ដែលកំណត់ថា ស្ត្រីគួរពិនិត្យដោយបុគ្គលិកវេជ្ជសាស្ត្រជាស្ត្រី និង/ឬក្នុងករណីដែលស្ត្រីត្រូវបានរឹតត្បិតការដើរហើរ ការមានបុគ្គលិកវេជ្ជសាស្ត្រជាស្ត្រី និងបុរស មានសារៈសំខាន់ណាស់។

ព័ត៌មានស្តីពីការផ្តល់ និងការចែកជំនួយសង្គ្រោះគួរផ្សព្វផ្សាយដល់សមាជិកសហគមន៍គ្រប់រូប ដោយនីតិវិធីសម្រាប់ការចុះឈ្មោះ និងការចែកជំនួយសង្គ្រោះ ត្រូវផ្តល់ភាពងាយស្រួលដល់បុគ្គល និងគ្រួសារទាំងអស់តាមរយៈការប្រើប្រាស់នីតិវិធីរដ្ឋបាលងាយស្រួល។ របបធ្វើការងារបានប្រាក់គួរពិចារណាពីក្រុមផ្សេងៗក្នុងសង្គម ពាក់ព័ន្ធនឹងអក្ខរភាព ចល័តភាព កិច្ចការគ្រួសារ

ដែលមិនទទួលបានប្រាក់ឈ្នួល និងការបែងចែកកិច្ចការ។ ផ្អែកតាមឧបសគ្គដែលរារាំងស្ត្រី និងក្រុមផ្សេងទៀតក្នុងការប្រើប្រាស់គ្រឹះស្ថានហិរញ្ញវត្ថុ វិធានការជំនួយហិរញ្ញវត្ថុអាចរួមមាន៖

- ការផ្តល់ជំនួយមូលនិធិតាមរយៈគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងស្ថាប័នប្រាក់សន្សំ។
- ការប្រើប្រាស់ជម្រើសផ្ទេរប្រាក់តាមទូរស័ព្ទចល័ត។
- ការគាំទ្រឱ្យស្ត្រីបង្កើតគណនីធនាគារផ្ទាល់ខ្លួន ឬគណនីរួមជាមួយដៃគូ/ស្វាមី។
- ការផ្តល់ជំនួយដល់ស្ត្រី និងក្រុមផ្សេងទៀតក្នុងសង្គម ក្នុងការទាមទារ ឬទទួលបានសិទ្ធិ និងការគាំទ្រផ្លូវច្បាប់ប្រសិនបើពួកគេខ្វះឯកសារចាំបាច់ ( ឯកសារបញ្ជាក់កម្មសិទ្ធិដីធ្លី)។

### ៤.២.៤.ប្រតិបត្តិការរុករក សង្គ្រោះ និងការជម្លៀស

**បញ្ជីត្រួតពិនិត្យប្រតិបត្តិការរុករក និងសង្គ្រោះ និងការជម្លៀសប្រកបដោយបរិយាប័ន្ន ៖**

- ប្រើប្រាស់ SADDD កម្រិតបុគ្គល(មិនមែនកម្រិតគ្រួសារ) សម្រាប់ការកំណត់អត្តសញ្ញាណជនដែលបាត់ខ្លួន។
- ប្រើប្រាស់មធ្យោបាយផ្សេងៗដើម្បីផ្សព្វផ្សាយព័ត៌មាន ស្តីពីការជម្លៀសដល់ជនមានពិការភាព អ្នកនិយាយភាសាផ្សេង និងអ្នកមិនសូវចេះអក្សរ ។
- ធានាថា សមាជិកសហគមន៍ និងមន្ត្រីគ្រប់គ្រងគ្រោះមហន្តរាយទទួលបានការបណ្តុះបណ្តាលស្តីពីការជួយដល់ជនមានពិការភាពដែលត្រូវជម្លៀស ដោយផ្តោតសំខាន់លើសារៈសំខាន់នៃការសាកសួរពួកគេអំពីការគាំទ្រដែលពួកគេត្រូវការ/ចង់បាន។ ការបណ្តុះបណ្តាលអាចរួមបញ្ចូលបច្ចេកទេសក្នុងការលើក និងបី/ពរជនមានពិការភាពផ្នែកចល័តភាព។
- ធានាថា មានជម្រើសមធ្យោបាយធ្វើដំណើរដែលផ្តល់ភាពងាយស្រួលដល់ជនមានពិការភាពផ្នែកចល័តភាពតាមរបៀបដែលមានសុវត្ថិភាព អាចទុកចិត្តបាន និងទាន់ពេលវេលា។
- ចាត់តាំងក្រុមដែលមានសមាសភាគចម្រុះ (បុរស-ស្ត្រី) សម្រាប់ប្រតិបត្តិការរុករក និងសង្គ្រោះដោយពិចារណាពីកត្តាវប្បធម៌ ដូចជា ក្នុងវប្បធម៌ខ្លះ មន្ត្រីរុករក និងសង្គ្រោះជាបុរសមិនគួរនិយាយជាលក្ខណៈឯកជនជាមួយស្ត្រីឡើយ។
- នីតិវិធីជម្លៀសផ្តោតអាទិភាពលើក្រុមក្នុងសង្គមដែលងាយរងគ្រោះបំផុត ដោយសារផលប៉ះពាល់នៃគ្រោះមហន្តរាយ ដោយផ្អែកតាមបរិបទមូលដ្ឋាន និងពិធីសាររបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។

## ៤.៣.យេនឌ័រក្នុងការស្តារឡើងវិញពីគ្រោះមហន្តរាយ

ការស្តារឡើងវិញពីគ្រោះមហន្តរាយ ជាឱកាសមួយក្នុងការផ្លាស់ប្តូរវិសមភាពនៃទំនាក់ទំនងសិទ្ធ និងលទ្ធភាពទទួលបានធនធាន និងលើកកម្ពស់សមភាពយេនឌ័រប្រកបដោយបរិយាប័ន្នសង្គមក្នុងសហគមន៍ដែលចំណុចនេះពាក់ព័ន្ធនឹងការកំណត់ទស្សនវិស័យច្បាស់លាស់ សម្រាប់ការស្តារឡើងវិញពីគ្រោះមហន្តរាយ ដែលលើកកម្ពស់សមភាពយេនឌ័រប្រកបដោយបរិយាប័ន្នគាំទ្រដោយក្របខ័ណ្ឌច្បាប់ និងគោលនយោបាយបែបបរិយាប័ន្ន។ បន្ទាប់ពីបានកំណត់បញ្ហាប្រឈមរបស់ក្រុមដែលងាយរងគ្រោះដោយសារផលប៉ះពាល់នៃគ្រោះមហន្តរាយ កម្មវិធីស្តារឡើងវិញអាចផ្តល់ការគាំទ្រចំគោលដៅដើម្បីបង្កើនភាពធន់របស់ក្រុមសំខាន់ៗក្នុងសង្គមទៅនឹងគ្រោះមហន្តរាយនាពេល

អនាគត ដូច្នេះការស្តារឡើងវិញពីគ្រោះមហន្តរាយនឹងបង្កើនបរិយាប័ន្នសង្គមយូរអង្វែង និងការអភិវឌ្ឍប្រកបដោយចីរភាព។

### ៤.៣.១.ការប៉ាន់ប្រមាណតម្រូវការក្រោយពេលគ្រោះមហន្តរាយ

ការប៉ាន់ប្រមាណតម្រូវការក្រោយពេលគ្រោះមហន្តរាយ (PDNA) ជាក្របខណ្ឌគ្រប់ជ្រុងជ្រោយសម្រាប់វាយតម្លៃផលប៉ះពាល់នៃគ្រោះមហន្តរាយមួយលើគ្រប់វិស័យ។ ការវាយតម្លៃនេះផ្អែកលើការប្រមូលទិន្នន័យបឋម ដូចជា តាមរយៈក្រុមពិភាក្សា និងកិច្ចសម្ភាសន៍ និងប្រភពបន្ទាប់បន្សំ ដូចជាជំរឿនរបស់រដ្ឋាភិបាល និងការអង្កេតគ្រួសារជាប្រចាំ ដែលអាចផ្តល់មូលដ្ឋានសម្រាប់ការស្វែងយល់ពីផលប៉ះពាល់នៃគ្រោះមហន្តរាយ។ ជាញឹកញាប់ ការវាយតម្លៃនេះធ្វើឡើងក្នុងរយៈពេល ៧២ ម៉ោងក្រោយពេលគ្រោះមហន្តរាយ រួចទើបធ្វើឡើងនៅចន្លោះពេលវេលាកំណត់នៅពេលក្រោយមកទៀត។ ការវាយតម្លៃនេះនឹងផ្តល់ព័ត៌មានសំខាន់ៗស្តីពីផលប៉ះពាល់ផ្សេងៗនៃគ្រោះមហន្តរាយលើក្រុមចម្រុះក្នុងសង្គមដែលគេប្រើប្រាស់សម្រាប់កំណត់អាទិភាពនៃវិធានការស្តារឡើងវិញ។

**បញ្ហាប្រឈម និងដំណោះស្រាយក្នុងការប្រមូលទិន្នន័យក្រោយពេលគ្រោះមហន្តរាយ**

| បញ្ហាប្រឈម | ដំណោះស្រាយ |
| --- | --- |
| ការពឹងផ្អែកជ្រុលលើទិន្នន័យកម្រិតគ្រួសារ (ពីការអង្កេតគ្រួសារ) ធ្វើឱ្យមានការប៉ាន់ស្មានទាបអំពីការខាតបង់ទ្រព្យសម្បត្តិរបស់ស្ត្រី។ ជាញឹកញាប់ការសម្ភាសន៍មេគ្រួសារធ្វើឱ្យមានភាពលម្អៀងលើបុរស និងជារឿយៗ មិនរួមបញ្ចូលជនគ្មានផ្ទះសម្បែង ជនទេសន្តរប្រវេសន៍ ឬអ្នករស់នៅទីដាច់ស្រយាល។ | - ប្រើប្រាស់បច្ចេកទេសផ្សេងៗក្នុងការអង្កេត ដូចជា ការអង្កេតតាមទូរស័ព្ទ។<br>- ប្រើប្រាស់បុគ្គល (មិនមែនគ្រួសារ) ជាឯកតានៃការវិភាគ។<br>- កត់ត្រាការខាតបង់តិចតួចក្នុងគ្រួសារដែលមានតម្លៃខ្ពស់ ( ម៉ាស៊ីនដេរ) ព្រោះការខាតបង់ទាំងនេះជាចំណែកដ៏ធំនៃទ្រព្យសម្បត្តិរបស់ស្ត្រី។ |
| ទំនាក់ទំនងរវាងភាពបន្ទាន់បន្ទុកពេលវេលាសម្រាប់អ្នកតបសម្ភាសន៍ និងគុណភាព និងបរិមាណនៃទិន្នន័យដែលប្រមូលបាន។ | ប្រើប្រាស់ការសិក្សាសេរីកាលក្រោយពេលគ្រោះមហន្តរាយ ដើម្បីពិនិត្យមើលផលប៉ះពាល់យូរអង្វែង និងមិនថិតថេរនៃគ្រោះមហន្តរាយ។ |
| កង្វះទិន្នន័យដើមគ្រាដែលបែងចែកជាប្រភេទ និងស៊ីសង្វាក់គ្នាក្នុងតំបន់រងផលប៉ះពាល់ដោយសារគ្រោះមហន្តរាយ រាំងស្ទះការវិភាគនិន្នាការ។ | បញ្ជ្រាបយេនឌ័រប្រកបដោយបរិយាប័ន្នសង្គមក្នុងការប្រមូល និងការប្រើប្រាស់ទិន្នន័យនៅថ្នាក់មូលដ្ឋាន ថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ។ |
| SADDD ដែលប្រមូលបានមិនត្រូវបានលម្អិតគ្រប់គ្រាន់នៅកម្រិតមូលដ្ឋាន ដើម្បីជួយដល់វិធានការស្តារឡើងវិញ។ | ប្រមូល SADDD លម្អិតនៅកម្រិតសហគមន៍ (ប្រសិនបើអាច)។ |

| | |
|---|---|
| អ្នកប្រមូលទិន្នន័យមិនស្ទរមានឯកទេស ឬឆន្ទៈក្នុងការប្រមូលទិន្នន័យស្តីពីបញ្ហារសើប ដូចជាទំនោរផ្លូវភេទ និងមេរោគអេដស៍។ | រៀបចំការបណ្តុះបណ្តាលស្តីពីបរិយាប័ន្នសង្គម សម្រាប់អ្នកប្រមូលទិន្នន័យក្នុងដំណាក់កាលត្រៀមបង្ការគ្រោះមហន្តរាយ។ |

វិធានការពិនិត្យតាមដាន និងវាយតម្លៃ ដូចជា PDNAs ជាផ្នែកចុងក្រោយនៃវដ្តគ្រប់គ្រងគ្រោះមហន្តរាយ។ ក្រុមនៅថ្នាក់មូលដ្ឋាន ថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិអាចប្រើប្រាស់លទ្ធផលពី PDNAs សម្រាប់ជាមូលដ្ឋាននៃកម្មវិធីស្តារឡើងវិញ និងវិធានការត្រៀមបង្ការគ្រោះមហន្តរាយនាពេលអនាគតដូចជាក្រុមអាចវិភាគលទ្ធផលនៃPDNAsដើម្បីកំណត់រកផលប៉ះពាល់នៃប្រតិបត្តិការសង្គ្រោះបន្ទាន់ និងការឆ្លើយតបគ្រោះមហន្តរាយលើទំនាក់ទំនងយេនឌ័រក្នុងសហគមន៍ និងផ្តល់មូលដ្ឋានដល់ការរៀបចំកម្មវិធីស្តារឡើងវិញដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ។

### ៤.៣.២.កម្មវិធីស្តារឡើងវិញ

កម្មវិធីស្តារឡើងវិញជាគម្រោងសង្គម សេដ្ឋកិច្ច និងបរិស្ថានរយៈពេលវែងដើម្បីស្តារឡើងវិញពីផលប៉ះពាល់នៃគ្រោះមហន្តរាយ និងកសាងសហគមន៍ឱ្យមានភាពធន់ជាងមុន។ ការបង្កើតកម្មវិធីនេះគួរផ្អែកតាមការវិភាគPDNAs និងការពិគ្រោះយោបល់ជាប្រចាំនិងប្រកបដោយអត្ថន័យជាមួយក្រុមសហគមន៍ដែលតំណាងឱ្យផលប្រយោជន៍របស់ក្រុមសំខាន់ៗក្នុងសង្គម ដូចជាគណៈកម្មាធិការស្ត្រីក្នុងមូលដ្ឋាន។ ការលើកកម្ពស់ការចូលរួមរបស់ក្រុមមានតំណាងភាគតិចក្នុងការរៀបចំផែនការស្តារឡើងវិញពីគ្រោះមហន្តរាយ ការរៀបចំថវិកា និងការអនុវត្តជាចំណុចសំខាន់ក្នុងការរៀបចំការឆ្លើយតបគ្រោះមហន្តរាយប្រកបដោយបរិយាប័ន្ន ដែលអាចធ្វើឱ្យមានការផ្លាស់ប្តូរសង្គមយូរអង្វែង។

**បញ្ជីត្រួតពិនិត្យកម្មវិធីស្តារឡើងវិញដែលប្រកបដោយបរិយាប័ន្នៈ**

- វិភាគ SADDD ដើម្បីកំណត់តម្រូវការចម្រុះរបស់ក្រុមក្នុងសង្គម និងបង្កើតបទបញ្ញត្តិ និងចំណុចអាទិភាពនៃកម្មវិធីស្តារឡើងវិញ។
- ធានាថា ជំនួយលំនៅដ្ឋាន ប្រាក់កាក់ និងស្បៀងអាហារត្រូវបានផ្តល់ជូនប្រជាជនគ្រប់រូបរួមទាំងអ្នកដែលគ្មានប័ណ្ណកម្មសិទ្ធិដីធ្លី ដូចជា ជនអនាថា ឬជនទេសន្តរប្រវេសន៍ដែលគ្មានឯកសារបញ្ជាក់។
- បន្តផ្តល់ការគាំទ្រផ្នែកចិត្តសង្គម និងសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ។
- បន្តផ្តល់សម្ភារ និងព័ត៌មានដែលបំពេញតម្រូវការសុខភាពបន្តពូជរបស់ក្រុមចម្រុះរួមទាំងក្រុម LGBTI។
- លើកកម្ពស់ការចូលរួមរបស់ក្រុមដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារគ្រោះមហន្តរាយក្នុងការបង្កើត និងអនុវត្តផែនការ និងកម្មវិធីស្តារឡើងវិញ។
- ជំរុញការចូលរួមរបស់ក្រុមមានតំណាងតិចតួចក្នុងសង្គម ដូចជា ស្ត្រី ក្នុងការកសាងឡើងវិញដោយផ្តល់សំណងជំងឺចិត្តសមស្រប និងផ្តោតការយកចិត្តទុកដាក់លើកិច្ចការគ្រួសារដែលមិនទទួលបានប្រាក់ឈ្នួលរបស់ពួកគេ។

- កម្មវិធីស្តារឡើងវិញមិនត្រឹមតែជួយឱ្យសហគមន៍កសាងរបរចិញ្ចឹមជីវិត និងហេដ្ឋារចនាសម្ព័ន្ធសង្គម និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តឡើងវិញក្រោយពេលគ្រោះមហន្តរាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើតឱកាសសម្រាប់ការពង្រឹងសហគមន៍ឱ្យកាន់តែមានបរិយាប័ន្នទៀតផង។ ចំណុចនេះពាក់ព័ន្ធនឹងការគាំទ្រដល់ក្រុមក្នុងសង្គមដែលត្រូវបានផាត់ចេញកន្លងមកឱ្យទទួលបានសេវាកសាងរបរចិញ្ចឹមជីវិតដែលមាននិរន្តរភាព និងភាពធន់ ដើម្បីចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តក្នុងសហគមន៍។ សហគមន៍បែបបរិយាប័ន្នដែលមានកម្មវិធី និងការធ្វើសេចក្តីសម្រេចចិត្តដោយមានការចូលរួមស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ នឹងត្រៀមខ្លួនបានល្អក្នុងការកាត់បន្ថយគ្រោះថ្នាក់ និងឆ្លើយតបគ្រោះមហន្តរាយ។

ចំណុចត្រូវចងចាំ ៖ ការបញ្ជ្រាបយេនឌ័រប្រកបដោយបរិយាប័ន្នក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ

- ការគ្រប់គ្រងគ្រោះមហន្តរាយជាឱកាសក្នុងការ "ស្តារឡើងវិញឱ្យប្រសើរជាងមុន" ដោយធានាថាក្រុមទាំងអស់ក្នុងសង្គមមានលទ្ធភាពស្មើភាពក្នុងការទទួលបានសេវា និងចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត។
- SADDD មានសារៈសំខាន់សម្រាប់ការបង្កើនវិធានការដែលមានប្រសិទ្ធភាពក្នុងការឆ្លើយតប និងស្តារឡើងវិញពីគ្រោះមហន្តរាយ និងការពិនិត្យតាមដាន និងវាយតម្លៃប្រកបដោយបរិយាប័ន្ន។
- ការយល់ពីភាពងាយរងគ្រោះ និងសមត្ថភាពរបស់ក្រុមក្នុងសង្គមនឹងផ្តល់មូលដ្ឋានសម្រាប់យុទ្ធសាស្ត្រផ្សព្វផ្សាយ ការគាំទ្រការឆ្លើយតបគ្រោះមហន្តរាយ និងកម្មវិធីស្តារឡើងវិញ។
- ការកសាងសមត្ថភាពស្តីពីបរិយាប័ន្នសង្គម និងសមភាពយេនឌ័រជាគន្លឹះសម្រាប់មន្ត្រីគ្រប់កម្រិតដែលធ្វើការងារពាក់ព័ន្ធនឹងការគ្រប់គ្រងគ្រោះមហន្តរាយ។

## ៥.ឧបសម្ព័ន

ឯកសារបន្ថែមសម្រាប់ការដាក់បញ្ចូលសមភាពយេនឌ័រប្រកបដោយបរិយាប័ន្នសង្គមក្នុងវិធានការស្តារឡើងវិញ

| ឯកសារបន្ថែម | ព័ត៌មានស្តីពីវិធានការស្តារឡើងវិញប្រកបដោយបរិយាប័ន្ន |
|---|---|
| **បញ្ជីត្រួតពិនិត្យ** | |
| ADB. ២០១៩. គន្លឹះស្តីពីយេនឌ័រ ៖ ការគ្រប់គ្រងគ្រោះមហន្តរាយដែលមានបរិយាប័ន្នយេនឌ័រ។ | - ហេដ្ឋារចនាសម្ព័ន្ធសហគមន៍<br>- ការសាងសង់លំនៅដ្ឋានឡើងវិញ<br>- ការស្តារបរចិញ្ចឹមជីវិត<br>- សុខភាព<br>- ការអប់រំ |
| UN Women & UNDP. ២០១៨ យេនឌ័រ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅអឺរ៉ុប និងអាស៊ីកណ្តាល។ | - ហេដ្ឋារចនាសម្ព័ន្ធសហគមន៍<br>- ការស្តារបរចិញ្ចឹមជីវិត<br>- បរិយាប័ន្នហិរញ្ញវត្ថុ |
| **ករណីសិក្សា** | |
| GFDRR ២០១៨ សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រីក្នុងការស្តារឡើងវិញពីគ្រោះមហន្តរាយ ។ | - ការពង្រឹងភាពធន់ផ្នែកហិរញ្ញវត្ថុរបស់ប្រជាជនក្រីក្របំផុតក្នុងប្រទេសអ៊ុយហ្គង់ដាតាមរយៈកិច្ចការពារសង្គមដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ។ |
| World Bank & GFDRR. ២០២១. ទិដ្ឋភាពយេនឌ័រក្នុងហានិភ័យគ្រោះមហន្តរាយ និងភាពធន់។ | - កិច្ចការពារសង្គមដែលមានភាពបត់បែន ឬកម្មវិធីកិច្ចការពារសង្គមថ្មីដែលអាចពង្រីកបន្ថែមដើម្បីឆ្លើយតបនឹងគ្រោះមហន្តរាយ។ |

រៀបចំដោយ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

ឧបត្ថម្ភ និងគាំទ្រដោយ:

បោះពុម្ពផ្សាយ នៅខែវិច្ឆិកា ឆ្នាំ២០២១